សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស

លីកាដូ

LICADHO

CAMBODIAN LEAGUE FOR THE
PROMOTION AND DEFENSE OF
HUMAN RIGHTS



# ការជម្រះក្តីកំបាំងមុខឆ្នាំ២០១៣៖ បច្ចុប្បន្នភាព ស្តីពី សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ និងវិបត្តិក្នុងការដឹកជញ្ជូនពិរុទ្ធជននៅកម្ពុជា

របាយការណ៍ចេញ
ខែឧសភា ឆ្នាំ២០១៣

# ការជម្រះក្ដីកំបាំងមុខឆ្នាំ២០១៣: បច្ចុប្បន្នភាព ស្ដីពីសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍ និងវិបត្តិក្នុងការដឹកជញ្ជូនពិរុទ្ធជននៅកម្ពុជា

របាយការណ៍ចេញខែឧសភា ឆ្នាំ២០១៣

**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនោះ ពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល។ លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង១២ ខេត្ត-រាជធានីផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

**ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តិ ដោយបុគ្គលអាជ្ញាធរ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារៈ**

បុគ្គលិកលីកាដូ ធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្ត ដោយអាជ្ញាធរ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

**ជំនួយផ្នែកវេជ្ជសាស្ត្រ និងសេវាកម្មសង្គមកិច្ចៈ**

ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ ចំនួន១៤ កន្លែង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**ការឃ្លាំមើលពន្ធនាគារៈ**

អ្នកស្រាវជ្រាវពន្ធនាគារ ធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាជនជាប់ឃុំ ទទួលបាននូវតំណាងផ្នែកច្បាប់។

**ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់ៈ**

ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

**គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងបណ្តាញនានាៈ**

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ ព្រមទាំងជួយពង្រឹងនូវសមត្ថភាពរបស់ពួកគេ ក្នុងការធ្វើយុទ្ធនាការ និងការតស៊ូមតិអំពីសិទ្ធិមនុស្ស។

**ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិៈ**

អ្នកហ្វឹកហ្វឺន និងអ្នកទាក់ទាញមតិគាំទ្រ ធ្វើការអប់រំដល់ក្រុមគោលដៅជាក់លាក់មួយចំនួន បណ្តាញគាំទ្រកិច្ចការពារសិទ្ធិមនុស្សនៅថ្នាក់មូលដ្ឋាន និងធ្វើការតស៊ូមតិសម្រាប់ការផ្លាស់ប្តូរសង្គម និងច្បាប់ ជាមួយស្ត្រី យុវវ័យ និងកុមារ។

**ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍ៈ**

ករណីរំលោភសិទ្ធិមនុស្ស ដែលស៊ើបអង្កេត ដោយអង្គការលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិត ជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។


**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខៈ (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារៈ (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែលៈ contact@licadho-cambodia.org
គេហទំព័រៈ www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho



សេចក្តីអធិប្បាយនៅក្នុងរបាយការណ៍នេះ ជាការទទួលខុសត្រូវទាំងស្រុងរបស់អង្គការ លីកាដូ ហើយមិនអាចយកទៅប្រើប្រាស់ក្នុងរូបភាពណាមួយ ដើម្បីឆ្លុះបញ្ចាំងពីទស្សនៈរបស់សហគមន៍អឺរ៉ុបឡើយ។

# មាតិកា


## សេចក្តីផ្តើម ទំព័រ១

## សំបុត្រធ្វើដំណើរឯកទិស ទំព័រ២

ការការពារសិទ្ធិជាមូលដ្ឋាន ទំព័រ២
ការវិវឌ្ឍន៍ដ៏តិចតួច ទំព័រ២
ករណីសិក្សា: "ប្រសិនបើខ្ញុំបានដឹងថាខ្ញុំនឹងត្រូវជាប់នៅទីនេះយូរបែបនេះ ខ្ញុំនឹងមិនទៅចូលរួមសវនាការ លើបណ្តឹងឧទ្ធរណ៍របស់ខ្ញុំទេ" ទំព័រ៤
បទពិសោធន៍នៅខេត្តបាត់ដំបង ទំព័រ៤
ទំនាក់ទំនងជាមួយសហគមន៍ និងក្រុមគ្រួសារត្រូវបានកាត់ផ្តាច់ ទំព័រ៥
ករណីសិក្សា: ការប្រឈមមុខនឹងរយៈពេល៥ឆ្នាំនៅពន្ធនាគារភ្នំពេញ ទំព័រ៥
ករណីសិក្សា: ការមិនមានមធ្យោបាយត្រលប់មកវិញ ទំព័រ៦

## ផលប៉ះពាល់នៅពន្ធនាគារនៅរាជធានីភ្នំពេញ ទំព័រ៧

ការផ្ទេរទៅកាន់មណ្ឌលអប់រំកែប្រែទី៣ ទំព័រ៦

## ស្ថិតិឆ្នាំ២០១២-២០១៣ ទំព័រ៨

ករណីសិក្សា: ករណីរបស់សំណាង៖ ការស្តានីតិសម្បទា ដែលបានសន្យាត្រូវបានផ្អាក ទំព័រ៩

## អតុល្យភាពខាងយេនឌ័រ ទំព័រ១០

## សេចក្តីសន្និដ្ឋាន និងយោបល់មួយចំនួន ទំព័រ១១

"ការរៀបចំជាក្រុម" នូវសវនាការលើបណ្តឹងឧទ្ធរណ៍ ទំព័រ១១
ការបង្កើតសាលាឧទ្ធរណ៍នៅក្នុងកម្រិតតំបន់ ទំព័រ១១
សាលាឧទ្ធរណ៍ចល័ត ទំព័រ១១
សវនាការតាមរយៈប្រព័ន្ធវីដេអូអ៊ីនធឺណិត ទំព័រ១១




គម្របមុខ៖ អ្នកជាប់ឃុំឃាំងតម្រង់ជួរនៅក្នុងពន្ធនាគារ ខេត្តកោះកុង
រូបថត/អង្គការលីកាដូ



រូបភាពពីមុខនៃសាលាឧទ្ធរណ៍តែមួយគត់នៃប្រទេសកម្ពុជា ដែលស្ថិតនៅក្នុងរាជធានីភ្នំពេញ

# សេចក្តីផ្តើម

នៅក្នុងឆ្នាំ២០១០ និងឆ្នាំ២០១២ អង្គការលីកាដូ បានធ្វើសេចក្តីរាយការណ៍ អំពីបញ្ហាសវនាការកំបាំងមុខលើបណ្តឹងឧទ្ធរណ៍នៅប្រទេសកម្ពុជា។ ជនជាប់ឃុំរាប់រយ ឬ រាប់ពាន់នាក់ត្រូវបានគេបដិសេធជាប្រព័ន្ធ នូវសិទ្ធិចូលរួមក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ក្នុងរឿងព្រហ្មទណ្ឌ ដែលជាសិទ្ធិមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ នៅក្នុងប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជា។

កាលពីឆ្នាំមុនអាជ្ញាធរតុលាការ និងអាជ្ញាធរពន្ធនាគារ នៅទីបំផុតបានចាប់ផ្តើមលើកយកបញ្ហានេះមកពិភាក្សារកដំណោះស្រាយ ទោះជាការដោះស្រាយនេះ អាចនឹងកើតមានបញ្ហាផ្សេងទៀតក៏ដោយ។

នៅក្នុងរបាយការណ៍សកម្មភាពប្រចាំឆ្នាំ២០១២[១] របស់អគ្គនាយកដ្ឋានពន្ធនាគារ ដែលបានចេញផ្សាយថ្មីៗនេះ បានរាយការណ៍ថា អគ្គនាយកដ្ឋាននេះ បានធ្វើការដឹកជញ្ជូនជនជាប់ឃុំចំនួន ៦១៩ នាក់មកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍ នៅរាជធានីភ្នំពេញក្នុងនោះ មានជនជាប់ឃុំចំនួន ៤៧៥ នាក់ ត្រូវបានដឹកចេញមកពីតាមបណ្តាខេត្ត។ ជាការពិត នេះជាការកែលំអមួយគួរឲ្យកោតសរសើរ ដែលស្ទើរតែមានចំនួន ២ ដងនៃចំនួនអ្នកជាប់ឃុំត្រូវបានដឹកជញ្ជូនមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍ នៅអំឡុងឆ្នាំ២០១០[២]។

លើសពីនេះ ការស្រាវជ្រាវរបស់អង្គការលីកាដូ បានបង្ហាញថា ភាគច្រើននៃអ្នកជាប់ឃុំ ដែលត្រូវដឹកជញ្ជូនទៅកាន់សាលាឧទ្ធរណ៍នៅរាជធានីភ្នំពេញ ធ្វើឡើងដោយមិនបង់ថ្លៃ[៣]។

អ្វីដែលរបាយការណ៍នេះមិនបានលើកឡើង គឺចំនួនជនជាប់ឃុំដែលត្រូវបានដឹកត្រឡប់ទៅកាន់ពន្ធនាគារ នៅតាមបណ្តាខេត្តវិញ បន្ទាប់ពីបានចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍ របស់អ្នកទាំងនោះ។ជាការពិតនេះ ប្រហែលជាមានចំនួនតិចតួច(ជាពិសេសបើមិនបានបង់លុយ)។

នេះជាបញ្ហាសំខាន់មួយដោយសារហេតុផលចំនួន២។

ហេតុផលទី១ ជនជាប់ឃុំ (ជាពិសេសជនជាប់ឃុំដែលមានជីវភាពក្រីក្រ) ពឹងផ្អែកទាំងស្រុងទៅលើក្រុមគ្រួសារ និងមិត្តភ័ក្តិសម្រាប់ជីវភាពរស់នៅ នៅក្នុងពន្ធនាគារ។ របបអាហារតាមបទដ្ឋានពន្ធនាគារ ថ្នាំសង្កូវ ប្រាក់កាសព្រមទាំងធនធានសម្ភារៈ មិនមានគ្រប់គ្រាន់ឡើយ ហើយជនជាប់ឃុំត្រូវការជំនួយពីខាងក្រៅ។ ការកាត់ទំនាក់ទំនងជនជាប់ឃុំ ពីក្រុមគ្រួសាររបស់ពួកគេ ក៏ជាការកាត់ទំនាក់ទំនងរបស់អ្នកទាំងនោះពីសហគមន៍ផងដែរ ដែលធ្វើឲ្យពួកគេរិតតែអាចប្រព្រឹត្តបទល្មើសជាថ្មីម្តងទៀត បន្ទាប់ពីអ្នកទាំងនោះត្រូវបានដោះលែង ហើយ

[១] អគ្គនាយកដ្ឋានពន្ធនាគារ របាយការណ៍ប្រចាំឆ្នាំ២០១២ និងទិសដៅសម្រាប់ឆ្នាំ២០១៣ ចេញផ្សាយក្នុងខែមីនា ឆ្នាំ២០១៣ (ការបកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការ)។
[២] របាយការណ៍ឆ្នាំ២០១១ របស់អគ្គនាយកដ្ឋានពន្ធនាគារ ចេញផ្សាយក្នុងខែកុម្ភៈ ឆ្នាំ២០១២ មិនបានលើកឡើងអំពីការផ្ទេរជនជាប់ឃុំមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍ឡើយ។
[៣] អង្គការលីកាដូ មិនបានសម្ភាសន៍គ្រប់អ្នកទោសដែលត្រូវបានបញ្ជូនមកសវនាការឧទ្ធរណ៍របស់អ្នកទាំងនោះនៅរាជធានីភ្នំពេញនោះទេ ប៉ុន្តែនៅពាក់កណ្តាលទី១ នៅឆ្នាំ២០១៣ ភាគច្រើននៃអ្នកដែលបានសម្ភាសន៍ ឆ្លើយថាអ្នកទាំងនោះត្រូវបានបញ្ជូនមកដោយឥតបង់ថ្លៃ។ ប៉ុន្តែ អ្នកជាប់ឃុំមួយចំនួន បន្តរាយការណ៍ថាអ្នកទាំងនោះបានចំណាយជាទូទៅប្រហែល ២០០ ដុល្លារ ទៅ ៣០០ ដុល្លារ។

នឹងមានលទ្ធភាពកាន់តែតិចទៅៗក្នុងការត្រឡប់ចូលក្នុងសង្គមវិញ។

ហេតុផលទី២ ពន្ធនាគារនៅជាយរាជធានីភ្នំពេញស្ថិតក្នុងចំណោមពន្ធនាគារ ដែលមានភាពចង្អៀតណែនបំផុតនៅក្នុងប្រទេសនេះ ដូច្នេះការដឹកជញ្ជូនពីខេត្តមករាជធានីភ្នំពេញ ហើយមិនសូវមានបញ្ជូនត្រឡប់ទៅខេត្តវិញ ទំនងជាធ្វើឲ្យស្ថានភាពនៅពន្ធនាគារនៅរាជធានីភ្នំពេញកាន់តែមានភាពធ្ងន់ធ្ងរឡើងៗ។

តាមការស្រាវជ្រាវពីអង្គការលីកាដូ បានរកឃើញថា ជនជាប់ឃុំភាគច្រើនបច្ចុប្បន្នកំពុងព្យាយាមយ៉ាងសកម្មដើម្បីចៀសវាងមិនឲ្យគេដឹកទៅកាន់រាជធានីភ្នំពេញ ដើម្បីចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍ឡើយ ធ្វើដូច្នេះ ពួកគេអាចនៅជិតក្រុមគ្រួសាររបស់ពួកគេនៅក្នុងខេត្ត។ នេះជាការវិវឌ្ឍន៍មួយគួរឲ្យព្រួយបារម្ភ។

នៅពេលដែលអគ្គនាយកដ្ឋានពន្ធនាគារបានបោះជំហានយ៉ាងល្អក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័ន ដើម្បីដឹកជញ្ជូនជនជាប់ឃុំទៅចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍នៅភ្នំពេញ ស្ថានភាពទាំងអស់នេះបញ្ជាក់យ៉ាងច្បាស់ថា នៅតែមានការងារច្រើនទៀតដែលត្រូវធ្វើ។

# សំបុត្រធ្វើដំណើរឯកទិស (ដំណើរមានតែទៅ មិនត្រលប់វិញ)

នៅឆ្នាំ២០១០ អង្គការលីកាដូ បានចេញនូវរបាយការណ៍មួយដែលមានចំណងជើងថា "ការជម្រះក្តីកំបាំងមុខ៖ សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ និងវិបត្តិ ក្នុងការដឹកជញ្ជូនអ្នកទោសនៅប្រទេសកម្ពុជា"[4]។ របាយការណ៍នេះ បានកត់សំគាល់ថា បណ្តាញដឹកជញ្ជូនពិរុទ្ធជនផ្លូវឆ្ងាយរបស់អគ្គនាយកដ្ឋានពន្ធនាគារស្ទើរតែគ្មានភាគច្រើនដោយសារតែខ្វះធនធានមនុស្ស និងសម្ភារៈសម្រាប់ការធ្វើដំណើរបែបនេះ។ នៅពេលដែលអ្នកជាប់ឃុំបានបង់ប្រាក់ នោះអ្នកទាំងនោះ នឹងត្រូវបានគេដឹកជញ្ជូនមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់ពួកគេនៅរាជធានីភ្នំពេញ។ ជាលទ្ធផលសវនាការបណ្តឹងឧទ្ធរណ៍ ជាញឹកញាប់ត្រូវបានធ្វើឡើងដោយកំបាំងមុខជនត្រូវចោទ ដែលជាការរំលោភយ៉ាងធ្ងន់ធ្ងរនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងជាការរំលោភបំពានច្បាប់ជាតិ។

អង្គការលីកាដូ បានចេញរបាយការណ៍បច្ចុប្បន្នភាពមួយនៅឆ្នាំ២០១២[5]។ របាយការណ៍នេះ បានរកឃើញថា ប្រព័ន្ធគ្រប់គ្រងពន្ធនាគារនៅតែខ្វះរថយន្តដឹកជញ្ជូន ប្រេងសាំង បុគ្គលិក និងមូលនិធិចាំបាច់សម្រាប់ដឹកជញ្ជូនពិរុទ្ធជន ទៅចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងនោះនៅរាជធានីភ្នំពេញ។ អង្គការលីកាដូ បានដាក់បញ្ចូលអនុសាសន៍មួយចំនួន ទៅក្នុងរបាយការណ៍ទាំងពីរនេះ រាប់ទាំងការមិនកំណត់ត្រឹមតែការបង្កើន ពង្រីកបណ្តាញដឹកជញ្ជូនដែលមានស្រាប់នោះទេ។

មន្ត្រីអគ្គនាយកដ្ឋានពន្ធនាគារបានទទួលស្គាល់ នូវការខ្វះខាតសេវាសម្រាប់ដឹកជញ្ជូនពិរុទ្ធជន ហើយសន្យាថានឹងលើកយកស្ថានភាពនេះ មកពិភាក្សារកដំណោះស្រាយ។ វិធានការវិជ្ជមានមួយចំនួនត្រូវបានចាត់ឲ្យមានឡើង ដោយមានកិច្ចសហការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា រាប់ទាំងការសាងសង់អគារថ្មីនៅសាលាឧទ្ធរណ៍ក្នុងរាជធានីភ្នំពេញ ការពង្រីកទីធ្លាការិយាល័យ និងការផ្គត់ផ្គង់សម្ភារៈបន្ថែមទៀត ដែលធ្វើឲ្យមានលទ្ធភាពផ្ទុកចៅក្រម និងក្រឡាបញ្ជីបានកាន់តែច្រើនថែមទៀត។ បន្ថែមពីលើនេះទិន្នន័យមួយត្រូវបានណែនាំឲ្យស្គាល់ដើម្បីគ្រប់គ្រងករណីថ្មីៗ។

អង្គការលីកាដូ បានចាប់ផ្តើមគាំទ្រដល់ជនជាប់ឃុំទាំងឡាយដែលចង់ស្នើសុំដឹកពួកគេទៅចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍នៅភ្នំពេញ។ ក៏ប៉ុន្តែជនជាប់ឃុំភាគច្រើន បានបង្ហាញនូវភាពស្ទាក់ស្ទើរដើម្បីធ្វើសំណើបែបនេះ ដោយសារភ័យខ្លាចថាអ្នកទាំងនោះនឹងមិនអាចវិលត្រឡប់មកកាន់ពន្ធនាគារខេត្តវិញ។ តាមការស្រាវជ្រាវចុងក្រោយរបស់អង្គការលីកាដូ បង្ហាញថាការភ័យខ្លាចរបស់អ្នកទាំងនោះមានមូលដ្ឋានសមហេតុសមផល។

## ការការពារសិទ្ធិជាមូលដ្ឋាន

តាមការក្រឡេកមើលដំបូង កិច្ចខិតខំប្រឹងប្រែងថ្មីៗរបស់អាជ្ញាធរពន្ធនាគារ ដើម្បីបង្កលទ្ធភាពឲ្យជនជាប់ឃុំចំនួនច្រើនថែមទៀតបានចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងនោះ គួរឲ្យទទួលបានការសរសើរ។ សិទ្ធិក្នុងការដាក់បណ្តឹងឧទ្ធរណ៍ គឺជាសិទ្ធិមូលដ្ឋានបំផុតមួយ ក្នុងចំណោមសិទ្ធិទទួលបានការជំនុំជម្រះក្តីទាំងអស់ក្នុងរឿងព្រហ្មទណ្ឌ ហើយនៅប្រទេសកម្ពុជា ការចូលរួមសវនាការរបស់ជនជាប់ចោទលើបណ្តឹងឧទ្ធរណ៍របស់ពួកគេក្នុងរឿង ព្រហ្មទណ្ឌគឺមានលក្ខណៈចាំបាច់ណាស់ ពីព្រោះតុលាការមានសិទ្ធិអំណាចពិនិត្យសាក្សី និងភស្តុតាងឡើងវិញ[6]។ ច្បាប់កម្ពុជាតម្រូវផងដែរថាជនជាប់ឃុំជាប់បណ្តឹងឧទ្ធរណ៍ "ត្រូវតែផ្ទេរនៅក្នុងរយៈពេលយ៉ាងខ្លីបំផុតតាមបញ្ជារបស់អគ្គព្រះរាជអាជ្ញា ឲ្យទៅនៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ដែលនៅជិតជាងគេបំផុត នៃទីស្នាក់ការរបស់សាលាឧទ្ធរណ៍"[7]។ ការចូលរួមសវនាការមិនមែនជាជម្រើសស្រេចតែចិត្តទេ។

**នៅពេលថ្មីៗនេះ អង្គការលីកាដូ បានជួបជនជាប់ឃុំ នៅមណ្ឌលអប់រំកែប្រែទី១ និងមណ្ឌលអប់រំកែប្រែទី២ ដែលបានធ្វើដំណើរពីខេត្តសៀមរាប បាត់ដំបង កំពត និងខេត្តកំពង់ស្ពឺ ដើម្បីមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់ពួកគេ។ គ្មានជនជាប់ឃុំណាម្នាក់ត្រូវបានផ្តល់ឱកាសឲ្យវិលត្រឡប់ទៅកាន់ពន្ធនាគារខេត្តវិញឡើយ។**

[4] របាយការណ៍សង្ខេបអង្គការលីកាដូ ខែកុម្ភៈ ឆ្នាំ២០១០។
[5] ការជម្រះក្តីកំបាំងមុខ ឆ្នាំ២០១២៖ បច្ចុប្បន្នភាពស្តីពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ និងវិបត្តិក្នុងការដឹកជញ្ជូនពិរុទ្ធជននៅកម្ពុជា របាយការណ៍សង្ខេបអង្គការលីកាដូ ខែមេសា ឆ្នាំ២០១២។
[6] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយត្រង់មាត្រា ១៤(៥) ដែលត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់កម្ពុជា តាមរយៈរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា ៣១។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាត្រង់មាត្រា ៣៧៥។
[7] នីតិវិធីព្រហ្មទណ្ឌត្រង់មាត្រា ៣៨៩។

នៅពេលរបាយការណ៍ឆ្នាំ២០១០ របស់អង្គការលីកាដូ ត្រូវបានបោះពុម្ពផ្សាយ គឺមានតែ ជនជាប់ឃុំដែលអាចចំណាយលុយកាក់សម្រាប់ដឹកជញ្ជូនដោយខ្លួនឯងបានប៉ុណ្ណោះ អាចត្រៀមលក្ខណៈទៅចូលរួមសវនាការលើបណ្ដឹងឧទ្ធរណ៍របស់អ្នកទាំងនោះ នៅភ្នំពេញ។ វាពិតណាស់ យោងតាមឯកឧត្តម គុយ ប៊ុនសន អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារបានមានប្រសាសន៍ថាកាលពីពេលមុនៗជនជាប់ឃុំជាប់បណ្ដឹងឧទ្ធរណ៍ ត្រូវបានផ្ទេរមកនៅជិតសាលាឧទ្ធរណ៍ "ត្រឹមតែក្នុងករណីលើសពី ១០% ប៉ុណ្ណោះ ករណីភាគច្រើននៅពេលដែលមេធាវីរបស់អ្នកទាំងនោះបានដាក់សំណើ ឬនៅពេលទទួលបានមូលនិធិក្រៅពីថវិកាពន្ធនាគារ" [៨]។

អាជ្ញាធរកម្ពុជា ទំនង ជាកំពុងចាត់វិធានការបន្ថែមទៀតផងដែរ ដើម្បីកែលំអស្ថានភាពនេះ។ នៅក្នុងរបាយការណ៍ឆ្នាំ២០១២ របស់ខ្លួន អគ្គនាយកដ្ឋានពន្ធនាគារបានទទួលស្គាល់ការខ្វះខាត ដែលនៅតែបន្តកើតមាននូវសេវាដឹកជញ្ជូន ហើយបានដាក់បញ្ចូលបញ្ហានេះទៅក្នុងទិសដៅសម្រាប់ឆ្នាំ២០១៣ ដើម្បី "ត្រៀមខ្លួនជានិច្ចសម្រាប់ផ្ដល់សេវាដឹកជញ្ជូនដល់ជនជាប់ឃុំ ដែលត្រូវដឹកចេញពីពន្ធនាគារមួយទៅកាន់ពន្ធនាគារមួយផ្សេងទៀត ព្រមទាំងដឹកទៅកាន់សាលាឧទ្ធរណ៍ និងតុលាការកំពូល"។ របាយការណ៍នេះ ធ្វើការកត់សំគាល់ផងដែរថា អគ្គនាយកដ្ឋានពន្ធនាគារបានស្នើសុំប្រេងម៉ាស៊ូតចំនួន ២,០០០ លីត្រ និងប្រេងម៉ាស៊ីនចំនួន ៣០ លីត្រ សម្រាប់ដឹកជញ្ជូនជនជាប់ឃុំទៅកាន់សាលាឧទ្ធរណ៍ ប៉ុន្តែមិនទាន់មានសេចក្ដីសម្រេចណាមួយត្រូវបានធ្វើឡើង ដើម្បីឆ្លើយតបទៅនឹងសំណើនេះ នៅឡើយទេ។

ក៏ប៉ុន្តែ ការផ្ដល់មធ្យោបាយដឹកជញ្ជូនទៅចូលរួមសវនាការលើបណ្ដឹងឧទ្ធរណ៍ អាចដំណើរការល្អក្នុងករណីដែលជនជាប់ឃុំ អាចវិលត្រឡប់មកកាន់ពន្ធនាគារខេត្តរបស់ពួកគេវិញផងដែរ។ បើមិនដូចនោះទេប្រព័ន្ធគ្រប់គ្រងបែបនេះ នឹងក្លាយជាលទ្ធផលអវិជ្ជមានទៅវិញ ដោយរារាំងទិសដៅក្នុងការបង្កលទ្ធភាព និងការលើកទឹកចិត្តដល់ជនជាប់ឃុំ ដើម្បីចូលរួមសវនាការលើបណ្ដឹងឧទ្ធរណ៍របស់អ្នកទាំងនោះ។ តាមការពិតប្រព័ន្ធរក្សាទុកជនជាប់ឃុំ ដែលត្រូវបានផ្ទេរឲ្យនៅរាជធានីភ្នំពេញបច្ចុប្បន្ន (ឬ ធ្វើការផ្ទេរពួកគេទៅកាន់មណ្ឌលអប់រំកែប្រែទី៣ នៅក្នុងខេត្តកំពង់ចាម) អាចធ្វើឲ្យជនជាប់ឃុំបាក់ទឹកចិត្ត មិនហ៊ានទៅចូលរួមសវនាការលើបណ្ដឹងឧទ្ធរណ៍ របស់អ្នកទាំងនោះយ៉ាងពិតប្រាកដ។

តួលេខជាក់លាក់អំពីចំនួនជនជាប់ឃុំ ដែលបានជាប់នៅក្នុងពន្ធនាគាររាជធានីភ្នំពេញ បន្ទាប់ពីបានចូលរួមសវនាការលើបណ្ដឹងឧទ្ធរណ៍មិនមានពិតប្រាកដ ហើយតួលេខទាំងនេះ មានការប្រែប្រួលចុះឡើង។ ក៏ប៉ុន្តែ មន្ត្រីពន្ធនាគារជាន់ខ្ពស់មួយរូបបានប្រាប់អង្គការលីកាដូ ឲ្យបានដឹងក្នុងខែមីនា ឆ្នាំ២០១៣ ថាមានជនជាប់ឃុំដែលបានផ្ទេរចំនួនជាង ១០០ នាក់ នៅជាប់ក្នុង មណ្ឌលអប់រំកែប្រែទី១ ពីព្រោះអគ្គនាយកដ្ឋានពន្ធនាគារ មិនមានថវិកាគ្រប់គ្រាន់សម្រាប់ដឹកជញ្ជូនអ្នកទាំងនោះត្រឡប់ទៅកាន់ពន្ធនាគារខេត្តវិញឡើយ។ អង្គការលីកាដូ បានទទួលព័ត៌មាន អំពីជនជាប់ឃុំក្នុងស្ថានភាពបែបនេះផងដែរ នៅក្នុងមណ្ឌលអប់រំកែប្រែទី២ ដោយបញ្ជាក់ថា យ៉ាងហោចណាស់ជនជាប់ឃុំចំនួន២៥%ក្នុងចំណោមជនជាប់ឃុំទាំងនេះ គឺត្រូវបានផ្ទេរចេញពីបណ្ដាខេត្តក្នុងឆ្នាំ២០១២ ដើម្បីចូលរួមសវនាការ ហើយបានជាប់ខ្លួននៅក្នុងពន្ធនាគាររាជធានីភ្នំពេញ។ តួលេខពិតប្រាកដអាចកើនឡើងខ្ពស់ជាងនេះ។

នៅពេលថ្មីៗនេះ អង្គការលីកាដូ បានជួបជនជាប់ឃុំនៅមណ្ឌលអប់រំកែប្រែទី១ និងមណ្ឌលអប់រំកែប្រែទី២ ដែលបានធ្វើដំណើរពីខេត្តសៀមរាប បាត់ដំបង កំពត និងខេត្តកំពង់ស្ពឺ ដើម្បីមកចូលរួមសវនាការលើបណ្ដឹងឧទ្ធរណ៍របស់ពួកគេ។



អ្នកជាប់ឃុំឈរតម្រង់ជួរនៅក្នុងពន្ធនាគារ ខេត្តកោះកុង

[៨] "ការលើកកំពស់កិច្ចសហការរវាងស្ថាប័នតុលាការ អយ្យការ និងពន្ធនាគារ និងការការពារសិទ្ធិកុមារក្នុងប្រព័ន្ធយុត្តិធម៌: របាយការណ៍សិក្ខាសាលាសហការរៀបចំដោយសាលាឧទ្ធរណ៍ ដោយមានការឧបត្ថម្ភពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា (OHCHR) និង UNICEF នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញកាលពីថ្ងៃទី៥-៧ ខែកញ្ញា ឆ្នាំ២០១២"។

គ្មានជនជាប់ឃុំណាម្នាក់ត្រូវបានផ្តល់ឱកាសឲ្យវិលត្រឡប់ទៅកាន់ពន្ធនាគារខេត្តវិញឡើយ។

ជនជាប់ឃុំម្នាក់ភេទប្រុសបានប្រាប់អង្គការលីកាដូ ថាគាត់ត្រូវបានផ្ទេរមកពីខេត្តបាត់ដំបងជាមួយជនជាប់ឃុំចំនួន ១៦ នាក់ ផ្សេងទៀត ដែលមកពីខេត្តបាត់ដំបងដូចគ្នា និងអ្នកខ្លះទៀតមកពីខេត្តកំពង់ចាម។ អ្នកជាប់ឃុំនោះ បានប្រាប់ថា ជនជាប់ឃុំទាំង ១៦ នាក់នោះ បានធ្វើដំណើរមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងនោះនៅភ្នំពេញ ហើយគ្មានជនជាប់ឃុំណាម្នាក់ក្នុងចំណោមអ្នកទាំង ១៦ នាក់ បានធ្វើដំណើរត្រឡប់ទៅកាន់ពន្ធនាគារខេត្តវិញឡើយ។

ជនជាប់ឃុំចំនួនច្រើនបំផុតដែលអង្គការលីកាដូបានធ្វើសម្ភាសន៍ បានរាយការណ៍ថា បុគ្គលិកពន្ធនាគារប្រាប់អ្នកទាំងនោះថា ពួកគេអាចធ្វើដំណើរទៅកាន់ពន្ធនាគារខេត្តរបស់ពួកគេវិញបាន ប្រសិនបើពួកគេបង់លុយរាប់រយដុល្លារសម្រាប់ម្នាក់ៗ។

ប្រធានពន្ធនាគារខេត្តភាគច្រើន បានប្រាប់អង្គការលីកាដូ ផងដែរថា ជនជាប់ឃុំ ដែលត្រូវបានអគ្គនាយកដ្ឋានពន្ធនាគារដឹកជញ្ជូនមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍ របស់អ្នកទាំងនោះ ជាញឹកញាប់មិនបានវិលត្រឡប់ទៅកាន់ពន្ធនាគារខេត្តវិញឡើយ ឬអាចវិលត្រឡប់ទៅវិញបានបន្ទាប់ពីមានការពន្យារពេលយ៉ាងយូរ។

"ប្រសិនបើខ្ញុំបានដឹងថាខ្ញុំនឹងត្រូវជាប់នៅទីនេះយូរបែបនេះ ខ្ញុំនឹងមិនទៅចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់ខ្ញុំទេ"។

"លីណា (មិនមែនឈ្មោះពិតគាត់ទេ) ត្រូវបានផ្ទេរពីពន្ធនាគារខេត្តកំពត មកកាន់រាជធានីភ្នំពេញក្នុងខែតុលា ឆ្នាំ២០១២ ដើម្បីចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់គាត់ ជាមួយសហចុងចោទចំនួន៥នាក់ផ្សេងទៀត។ ដោយសារលីណា ជាអនីតិជន (ក្រោម ១៨ ឆ្នាំ) លីណាត្រូវបានឃុំខ្លួននៅ មណ្ឌលអប់រំកែប្រែទី ២។ សហចុងចោទទាំង ៦ នាក់នេះកំពុងតែជាប់ឃុំនៅមណ្ឌលអប់រំកែប្រែទី១ និងមណ្ឌលអប់រំកែប្រែទី២ នៅជាយរាជធានីភ្នំពេញ។

លីណានិយាយថា ប្រសិនបើគាត់បាន ដឹងជាមុនថា គាត់នឹងត្រូវជាប់នៅមណ្ឌលអប់រំកែប្រែទី២ នេះ គាត់នឹងមិនទៅចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់គាត់ទេ។ ក្នុងរយៈពេល ៦ ខែកន្លងទៅនេះក្រុមគ្រួសាររបស់គាត់មានលទ្ធភាពមកសួរសុខទុក្ខគាត់បានតែម្តងគត់។ ចំណែកកាលឃុំខ្លួននៅខេត្តកំពត ក្រុមគ្រួសារបានមកជួបគាត់យ៉ាងតិចណាស់ ១ ខែបានម្តង។ លីណាត្រូវជាប់ទោសចំនួន ៥ ឆ្នាំទៀត។

## ការវិវឌ្ឍន៍ដ៏តិចតួច

បញ្ហាចំបងក្នុងប្រព័ន្ធដឹកជញ្ជូនទៅចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍នេះ បង្កើតជាការវិវឌ្ឍន៍ដ៏តិចតួចនៃបញ្ហានេះ រហូតមកដល់បច្ចុប្បន្ននេះ។ ប្រការសំខាន់បំផុតនោះ ប្រសិនបើបញ្ហានេះ មិនត្រូវបានលើកយកមកដោះស្រាយឆាប់ៗទេ នេះអាចមានន័យថា ប្រព័ន្ធដឹកជញ្ជូនដើម្បីទៅចូលរួមក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍នេះ ទីបំផុតនឹងមិនអាចទទួលបានផលជាវិជ្ជមាននោះទេ។

ដូចពាក្យសំដីលេចឮក្នុងចំណោមជនជាប់ឃុំ ដែលបាននិយាយថា ឱកាសចូលរួមសវនា-ការលើបណ្តឹងឧទ្ធរណ៍ ត្រូវចំនាយច្រើនបំផុត គឺហួសឆ្ងាយពីមធ្យោបាយរបស់ជនជាប់ឃុំនៅកម្ពុជាភាគច្រើនក្រៃលែង ដោយអ្នកទាំងនោះភាគច្រើននឹងឈានទៅដល់ការសន្និដ្ឋានមួយក្នុងចំណោមការសន្និដ្ឋានចំនួនពីរ៖ ទី១ គឺការមិនដាក់បណ្តឹងឧទ្ធរណ៍ទាល់តែសោះ ឬ ទី២ ដោយបណ្តោយឲ្យសវនាការលើបណ្តឹងឧទ្ធរណ៍ ប្រព្រឹត្តទៅដោយកំបាំងមុខអ្នកទាំងនោះ។

ដោយមានការគិតក្នុងចិត្តបែបនេះ ភាពស្មោះត្រង់នៃការព្យាយាមរបស់អគ្គនាយកដ្ឋានពន្ធនាគារ ក្នុងការបង្កលទ្ធភាពដល់ជនជាប់ឃុំឲ្យបានចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងនោះ គឺស្ថិតក្នុងស្ថានភាពស្រពិចស្រពិលយ៉ាងខ្លាំង។ នេះជាហេតុការណ៍មួយគួរឲ្យសោកសៅដែលថា កិច្ចខិតខំប្រឹងប្រែងទាំងឡាយ ដែលត្រូវបានរៀបចំឡើងជាក់ស្តែង ដើម្បីលើកកំពស់សិទ្ធិរបស់ជនជាប់ឃុំ នាំឲ្យមានការបោះបង់ជនជាប់ឃុំភាគច្រើនចោលក្នុងពន្ធនាគារចង្អៀតណែននៅជាយរាជធានីភ្នំពេញ ដែលនៅឆ្ងាយពីក្រុមគ្រួសាររបស់អ្នកទាំងនោះ ហើយអាចឲ្យអ្នកទាំងនោះមានឱកាសតិចតួចថានឹងបានវិលត្រឡប់ទៅខេត្តវិញ។ នេះជាការខកចិត្តដូចៗគ្នាដែលថា ប្រព័ន្ធធ្វើឲ្យប្រសើរឡើងនូវការប្រកាន់ខ្ជាប់នូវច្បាប់កម្ពុជាត្រូវបានរារាំងដោយបញ្ហាហិរញ្ញវត្ថុ ដែលតម្រូវឲ្យអ្នកក្រីក្របំផុតជាជនជាប់ឃុំ ជាអ្នកបង់ប្រាក់កាសទៅវិញ។

## បទពិសោធន៍នៅខេត្តបាត់ដំបង

ចំនួនជនជាប់ឃុំខ្ពស់បំផុត ដែលត្រូវបានដឹកមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងនោះ គឺមកពីពន្ធនាគារខេត្តបាត់ដំបង។ យោងតាមស្ថិតិរបស់អគ្គនាយកដ្ឋានពន្ធ-នាគារ មានការផ្ទេរចំនួន ១៨ លើក ដែលដឹកជនជាប់ឃុំបានចំនួនសរុប ៨០ នាក់។

តួលេខទាំងនេះ មិនមានការភ្ញាក់ផ្អើល ដោយសារតែខេត្តបាត់ដំបងមានពន្ធនាគារមួយក្នុងចំណោមពន្ធនាគារទាំងឡាយ នៅក្រៅរាជធានីភ្នំពេញ ដែលធំ និងមានផ្ទុកជនជាប់ឃុំចំនួនច្រើនជាងគេបំផុត។ ស្ថិតិរបស់អង្គការលីកាដូ បង្ហាញថា គិតមកត្រឹមខែមករា ឆ្នាំ២០១៣ ចំនួនជនជាប់ឃុំដែលកំពុងរង់ចាំសវនាការលើបណ្តឹងឧទ្ធរណ៍ក្នុងខេត្តបាត់ដំបង គឺមានតួលេខទាប។

ប៉ុន្តែតាមការធ្វើសម្ភាសន៍ជាមួយជនជាប់ឃុំមកពីខេត្តបាត់ដំបង អ្នកទាំងនោះបង្ហាញនូវព័ត៌មានខុសពីនេះ។ នេះហាក់ដូចជាជនជាប់ឃុំជាច្រើនដែលត្រូវបានដឹកជញ្ជូន បច្ចុប្បន្នអ្នកទាំងនេះកំពុងជាប់ខ្លួននៅក្នុងពន្ធនាគារនៅជាយរាជធានីភ្នំពេញ។ អ្វីដែលគួរឲ្យព្រួយបារម្ភបំផុតនោះ គឺជនជាប់ឃុំមួយចំនួននៅខេត្តបាត់ដំបងបានប្រាប់អង្គការលីកាដូ ថា អ្នកទាំងនោះលែងចង់ទៅចូលរួមក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍របស់ពួកគេទៀតហើយ ដោយសារតែអ្នកទាំង

នោះដឹងថាប្រសិនបើពួកគេ មិនអាចបង់ប្រាក់ធ្វើដំណើរត្រឡប់ទៅខេត្តវិញបានទេ ពួកគេនឹងត្រូវស្នាក់នៅពន្ធនាគារនៅជាយរាជធានីភ្នំពេញតទៅទៀត។ ជនជាប់ឃុំមួយចំនួនប្រាប់អង្គការលីកាដូ ថាពួកគេ ត្រូវបង្ខំចិត្តធ្វើដំណើរមកកាន់រាជធានីភ្នំពេញ ដើម្បីចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់ពួកគេ។

នៅក្នុងខែមករា អតីតប្រធានពន្ធនាគារខេត្តបាត់ដំបងមួយរូបបាន បញ្ជាក់ថា នៅពេលអគ្គនាយកដ្ឋានពន្ធនាគារ ធ្វើការដឹកជញ្ជូនជនជាប់ឃុំទៅចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងនោះ ពួកគេភាគច្រើនមិនចង់ធ្វើដំណើរទៅទេរហូតមកទល់បច្ចុប្បន្ននេះ។ លោកដែលជាអតីតប្រធានពន្ធនាគាររូបនោះ បានប្រាប់អង្គការលីកាដូថា ប្រសិនបើអ្នកទាំងនោះ មិនមានថវិកាចំណាយនោះទេ ពួកគេនឹងបន្តជាប់ឃុំនៅរាជធានីភ្នំពេញ ឬត្រូវផ្ទេរទៅកាន់មណ្ឌលអប់រំកែប្រែទី៣។

## ទំនាក់ទំនងជាមួយសហគមន៍ និងក្រុមគ្រួសារត្រូវបានកាត់ផ្តាច់

គោលការណ៍ ១៩ នៃអង្គភាពគោលការណ៍របស់អង្គការសហប្រជាជាតិសម្រាប់ការពារបុគ្គលគ្រប់រូបក្រោមទម្រង់នៃការឃុំខ្លួន ឬការកាត់ទោសឲ្យជាប់ពន្ធនាគារចែងថា "ជនជាប់ឃុំ ឬជនត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារ ត្រូវមានសិទ្ធិទទួលបាន ការមកសួរសុខទុក្ខជាពិសេស ពីសំណាក់សមាជិកទាំងឡាយនៃក្រុមគ្រួសាររបស់គេ និងធ្វើការប្រាស្រ័យទាក់ទងជាមួយសមាជិកនៃក្រុមគ្រួសារទាំងនោះ. . . "[៩]។ លើសពីនេះទៅទៀត គោលការណ៍ ២០ ចែងថា "ប្រសិនបើជនជាប់ឃុំ ឬជនត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារស្នើសុំដូចនោះមែន បើអាចធ្វើបានជននោះ តាមហេតុផលសមស្របត្រូវតែបានរក្សាទុកនៅទីកន្លែងឃុំខ្លួន ឬនៅទីកន្លែងកាត់ទោសឲ្យជាប់ពន្ធនាគារ ដែលនៅជិតលំនៅដ្ឋានធម្មតារបស់គេ"[១០]។




បន្ទប់សួរសុខទុក្ខផ្ទាល់នៅពន្ធនាគារ ខេត្តកំពង់ចាម

ចំពោះជនជាប់ឃុំកម្ពុជាភាគច្រើន ការដែលទទួលបានការមកសួរសុខទុក្ខពីសំណាក់ក្រុមគ្រួសារ ឬមិត្តភក្តិ គឺជាការផ្តល់នូវមធ្យោបាយរស់រានមានជីវិតដ៏សំខាន់មួយ។ នៅក្នុងប្រព័ន្ធគ្រប់គ្រងមួយដែលខ្វះធនធាន និងនៅតែមានអំពើ ពុករលួយ ជនជាប់ឃុំទាំងឡាយ ដែលគ្មានការជួយឧបត្ថម្ភពីខាងក្រៅពន្ធនាគារ គឺជាជនដែលងាយរងគ្រោះបំផុត។ នៅក្នុងស្ថានភាពបែបនេះ ជនជាប់ឃុំដែលគ្មានលុយកាក់ ឬគ្មានការជួយឧបត្ថម្ភពីខាងក្រៅ ត្រូវតែពឹងផ្អែកទាំងស្រុងទៅលើអ្វីដែលអាជ្ញាធរពន្ធនាគារបានផ្តល់ឲ្យ។ របបអាហារផ្តល់ពីពន្ធនាគារមានឱជារសមិនគ្រប់គ្រាន់ ខ្វះខាតទឹក ហើយសូម្បីតែការចាត់ចែងទទួលទានដំណេក ក៏ត្រូវបានគេកំណត់អាទិភាពតាមកម្រិតមធ្យោបាយហិរញ្ញវត្ថុផងដែរ។

ក្នុងចំណោមជនជាប់ឃុំដែលត្រូវបានសម្ភាសន៍ ដោយអង្គការលីកាដូ ហើយដែលបានជាប់ខ្លួននៅក្នុងពន្ធនាគារនៅជាយរាជធានីភ្នំពេញ បន្ទាប់ពីសវនាការលើបណ្តឹងឧទ្ធរណ៍ សុទ្ធតែបានពិពណ៌នាអំពីផលប៉ះពាល់ដល់ដំណើរមកសួរសុខទុក្ខពីសំណាក់ក្រុមគ្រួសាររបស់អ្នកទាំងនោះ។ ជនជាប់ឃុំខ្លះ មិនដែលបានទទួលការមកសួរសុខទុក្ខទាល់តែសោះចាប់តាំងពីបានផ្ទេរមកនៅរាជធានីភ្នំពេញ ដើម្បីចូលរួមសវនាការសាលាឧទ្ធរណ៍។

[៩] ត្រូវបានអនុម័តដោយមហាសន្និបាតសហប្រជាជាតិនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៨៨។
[១០] យោងឯកសារដូចគ្នានឹងជើងទំព័រទី៩។

## ការប្រឈមមុខនឹងរយៈពេល ៥ឆ្នាំនៅពន្ធនាគារភ្នំពេញ

នៅក្នុងឆ្នាំ២០១០ "ដារ៉ា" ភេទប្រុសអាយុ ២៣ឆ្នាំ (មិនមែនឈ្មោះពិតគាត់ទេ) ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន ៨ឆ្នាំពីបទប្លន់។ នៅពេលបណ្តឹងឧទ្ធរណ៍របស់គាត់ ត្រូវបានកំណត់ពេលបើកសវនាការក្នុងឆ្នាំ២០១២ គាត់មិនចង់ទៅចូលរួមសវនាការទេ។ នៅក្នុងពន្ធនាគារខេត្តបាត់ដំបង គាត់ឮគេថាជនជាប់ឃុំដែលត្រូវបានអគ្គនាយកដ្ឋានពន្ធនាគារដឹកជញ្ជូនជាញឹកញាប់មិនបានវិលត្រឡប់ទៅកាន់ខេត្តវិញទេ។ គាត់បានឮគេប្រាប់ផងដែរ ថាគាត់នឹងត្រូវបង់ប្រាក់១៥០ដុល្លារ ប្រសិនបើគាត់ចង់វិលត្រឡប់ទៅកាន់ពន្ធនាគារខេត្តបាត់ដំបងវិញ។ ដោយមានក្រុមគ្រួសាររបស់គាត់នៅជិត និងមកជួបសួរសុខទុក្ខគាត់យ៉ាងហោចណាស់ ២ ដងក្នុង ១ ខែ គាត់មានភាពស្ទាក់ស្ទើរក្នុងការប្រឈមនឹងហានិភ័យ។

ដារ៉ា និយាយថា នៅទីបញ្ចប់គាត់គ្មានជម្រើស ហើយថាគាត់ត្រូវបានបង្ខំចិត្តឲ្យមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់គាត់។ នៅពេលមកដល់មណ្ឌលអប់រំកែប្រែទី១ គាត់ត្រូវរង់ចាំអស់រយៈពេលជាង ៣ ខែមុន ពេលបើកសវនាការ ហើយចាប់ពីពេលនោះមក គ្មានអ្នកណាមួយបានលើកឡើងពីលទ្ធភាពក្នុងការវិលត្រឡប់ទៅកាន់ខេត្តបាត់ដំបងវិញឡើយ។

បច្ចុប្បន្ននេះ គាត់ត្រូវបានឃុំខ្លួនក្នុងមណ្ឌលអប់រំកែប្រែទី១ នេះអស់រយៈពេលជាង ៩ ខែមកហើយ ហើយក៏មិនដែលបានទទួលការមកសួរសុខទុក្ខពីក្រុមគ្រួសារឡើយ។ នៅខេត្តបាត់ដំបងម្តាយមីងរបស់គាត់បានមកមើលគាត់យ៉ាងហោចណាស់ ២ ដងក្នុង ១ ខែ ប៉ុន្តែ ក្រុមគ្រួសារ និងមិត្តភ័ក្តិរបស់គាត់ជាអ្នកក្រីក្រ ហើយមិនអាចលៃលកធ្វើដំណើរមកកាន់ភ្នំពេញបាន។ ដោយគ្មានអ្នកណាមកមើលគាត់ គាត់ក៏គ្មានលុយកាក់ចាយវាយ ហើយគាត់ត្រូវពឹងផ្អែកទាំងស្រុងទៅលើរបបឧបត្ថម្ភ មិនគ្រប់គ្រាន់ពីពន្ធនាគារ។

ទោសរបស់ ដារ៉ា មិនបានប្រែប្រួលឡើយក្រោយពីមានសវនាការលើបណ្តឹងឧទ្ធរណ៍ ដូច្នេះបើគាត់មិនត្រូវបានគេដឹកត្រឡប់ទៅកាន់ខេត្តបាត់ដំបងវិញទេ គាត់ត្រូវប្រឈម នឹងរយៈពេល ៥ ឆ្នាំទៀតនៅភ្នំពេញ ដោយគ្មានអ្នកក្រៅមកមើលគាត់។

ដារ៉ា ត្រូវបានគេដឹកមកកាន់ភ្នំពេញ ជាមួយនឹងជនជាប់ឃុំចំនួន ១៦ នាក់ផ្សេងទៀត - ១៤ នាក់ពីខេត្តបាត់ដំបង និង ពីរនាក់ពីខេត្តកំពង់ចាម អ្នកទាំងនេះមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់ពួកគេ។ គាត់ជឿថាជនជាប់ឃុំទាំង ១៦ នាក់ នេះកំពុងតែត្រូវបានឃុំខ្លួនក្នុងមណ្ឌលអប់រំកែប្រែទី១ នៅឡើយ។

## ការមិនមានមធ្យោបាយត្រលប់មកវិញ

"សុខ" និង "វុទ្ធី" (មិនមែនឈ្មោះពិតរបស់អ្នកទាំងពីរទេ) ត្រូវបានចាប់ខ្លួនក្នុងខែមេសា ឆ្នាំ២០១០ នៅខេត្តបាត់ដំបង ហើយត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួន ៤ ឆ្នាំពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ។ ជនជាប់ឃុំទាំង ២ នាក់នេះ ជាអនីតិជននៅអំឡុងពេលចាប់ខ្លួនដំបូង។

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១២ អ្នកទាំងពីរត្រូវបានអគ្គនាយកដ្ឋានពន្ធនាគារដឹកជញ្ជូនដោយឥតបង់ថ្លៃមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់ពួកគេ។ ចាប់តាំងពីពេលនោះមក ពួកគេត្រូវបានឃុំខ្លួននៅក្នុងមណ្ឌលអប់រំកែប្រែទី២ នៅជាយរាជធានីភ្នំពេញ ដោយគ្មានមធ្យោបាយនឹងវិលត្រឡប់ទៅកាន់ពន្ធនាគារខេត្តបាត់ដំបងវិញឡើយ។

នៅពេលបើកសវនាការលើបណ្តឹងឧទ្ធរណ៍ក្នុងខែធ្នូ ឆ្នាំ២០១២ ទោសអ្នកទាំងពីរត្រូវបានបន្ថយចំនួន ១ ឆ្នាំ ហើយអ្នកទាំងពីរនឹងត្រូវដល់ពេលដោះលែងនៅថ្ងៃទី២៨ ខែមេសា ខាងមុខនេះ។ ដោយខ្វះខាតថវិកា ឬមិនទទួលបានព័ត៌មានអំពីស្ថានភាពរាជធានីភ្នំពេញជាមុន អ្នកទាំងពីរនឹងមិនដឹងថានឹងត្រូវធ្វើអ្វីបន្ទាប់ពីមានការដោះលែង ឬមិនដឹងថាត្រូវត្រឡប់ទៅកាន់ខេត្តបាត់ដំបង វិញតាមវិធីណាទេ។

ចាប់តាំងពីពេលពួកគេត្រូវបានផ្ទេរមកកាន់រាជធានីភ្នំពេញ ក្រុមគ្រួសាររបស់ពួកគេមិនអាចមានលទ្ធភាពមកជួបសួរសុខទុក្ខពួកគេបានឡើយ។ ហើយរហូតដល់ពេលដែលអ្នកទាំងពីរត្រូវដោះលែង គឺមានរយៈពេល ៦ ខែហើយដែលអ្នកទាំងពីរមិនមានក្រុមគ្រួសារមកសួរសុខទុក្ខ។



ពន្ធនាគារនៅខេត្តកំពត

ជនជាប់ឃុំផ្សេងទៀតបាននិយាយថា ក្រុមគ្រួសាររបស់អ្នកទាំងនោះ មានលទ្ធភាពមកសួរសុខទុក្ខ ១ ដង ឬ ២ ដងប៉ុណ្ណោះ ដោយសារថវិកាមានកំណត់ ឬដោយសារតែពួកគេមិនអាចឈប់សំរាកពីការងារ ដើម្បីធ្វើដំណើរមកកាន់រាជធានីភ្នំពេញបាន។ ជាក់ស្តែងជនជាប់ឃុំទាំងឡាយដែលមិនអាចទទួលបានមធ្យោបាយដឹកជញ្ជូនត្រឡប់ទៅវិញបាន គឺទំនងជាអ្នកមកពីត្រកូលគ្រួសារក្រីក្រ ដែលគ្មានពេលវេលានិងធនធានសម្រាប់ធ្វើដំណើរមកសួរសុខទុក្ខពួកគេនៅពន្ធ-នាគាររាជធានីភ្នំពេញ។

ការឃុំខ្លួនក្នុងពន្ធនាគារនៅដាច់ឆ្ងាយពីក្រុមគ្រួសារ និងសហគមន៍របស់ពួកគេផ្តល់ផលអវិជ្ជមានជាច្រើន រាប់ទាំងឱកាសក្នុងការវិលចូលក្នុងសង្គមវិញប្រកបដោយជោគជ័យ និងបង្កលទ្ធភាពក្នុងការប្រព្រឹត្តិបទល្មើសមិនរាងចាល។ ប្រសិនបើជនជាប់ឃុំត្រូវបានគេផ្តល់ឲ្យនូវការត្រៀមរៀបចំសមរម្យសំរាប់ការដោះលែង នៅខណៈកំពុងឃុំខ្លួនក្នុងពន្ធនាគារនៅឡើយ រាប់ទាំងការបណ្តុះបណ្តាលជំនាញ និងការបន្ត ភ្ជាប់ទំនាក់ទំនងជាមួយក្រុមគ្រួសារ ឬ សហគមន៍ នោះឱកាសក្នុងការវិលចូលក្នុងសង្គមវិញប្រកបដោយជោគជ័យនឹងមានកំរិតខ្ពស់។ ការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារសមស្រប និងបណ្តាសហគមន៍អាចមានសារៈសំខាន់ ពិសេសសម្រាប់សុខុមាលភាព និងការវិលចូលក្នុងសង្គមវិញរបស់ជនជាប់ឃុំវ័យក្មេងនៅពេលអនាគត។

ជនជាប់ឃុំដែលអង្គការលីកាដូ បានធ្វើសម្ភាសន៍ ភាគច្រើនជាមនុស្សប្រុសវ័យក្មេង។ ពិតណាស់ជនជាប់ឃុំ ៥ នាក់ ក្នុងចំណោមអ្នកទាំងនោះ អះអាងថា ពួកគេមានអាយុក្រោម ១៦ ឆ្នាំ នៅពេលចាប់ខ្លួន។ ជនជាប់ឃុំមួយចំនួននៅតាមពន្ធនាគារខេត្ត បានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការជួយឧបត្ថម្ភមុនពេលដោះលែង។ មិនមានជនជាប់ឃុំណាម្នាក់ក្នុងចំណោមពួកគេបានទទួលការបណ្តុះបណ្តាល ឬការជួយឧបត្ថម្ភបែបនេះនោះទេ ចាប់តាំងពីអ្នកទាំងនោះបានមកដល់រាជធានីភ្នំពេញ។



បន្ទាល្អួសនៅមណ្ឌលអប់រំកែប្រែទី២ នៃរាជធានីភ្នំពេញ

# ផលប៉ះពាល់នៅពន្ធនាគារនៅរាជធានីភ្នំពេញ

ជនជាប់ឃុំ ដែលមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងនោះ ត្រូវបានផ្ទេរទៅកាន់មណ្ឌលអប់រំកែប្រែទី១ និងទី២ ព្រមទាំងទៅកាន់ពន្ធនាគារប៉េហ្ស៊ី (PJ) នៅជាយរាជធានីភ្នំពេញ និងពន្ធនាគារក្រុងតាខ្មៅជិតរាជធានីភ្នំពេញ។

នៅខណៈ ដែលប្រព័ន្ធពន្ធនាគារទូទាំងប្រទេសកម្ពុជាកំពុងផ្ទុកជនជាប់ឃុំចង្អៀតណែន មណ្ឌលអប់រំកែប្រែទី១ និងទី២ និងពន្ធនាគារក្រុងតាខ្មៅ គឺស្ថិតនៅក្នុងចំណោមពន្ធនាគារដែលចង្អៀតណែនជាងគេបំផុតនៅប្រទេសកម្ពុជា។ ម្យ៉ាងវិញទៀត មណ្ឌលអប់រំកែប្រែទី១ ទី២ ទី៣ និងទី៤ តាមទ្រឹស្តីត្រូវបានរៀបចំឡើង ដើម្បីផ្ទុកទណ្ឌិតដែលមានទោសធ្ងន់ និងរយៈពេលវែង។

យោងតាមការគណនាអង្គការលីកាដូ គិតមកដល់ត្រឹមខែមីនា ឆ្នាំ២០១៣ មណ្ឌលអប់រំកែប្រែទី១ កំពុងផ្ទុកចំនួន ១៦៤% នៃទំហំផ្ទុកនៃមណ្ឌលនេះ មណ្ឌលអប់រំកែប្រែទី២ ផ្ទុកចំនួន ២២៧% នៃទំហំផ្ទុកនៃមណ្ឌលនេះ។ ពន្ធនាគារក្រុងតាខ្មៅ ដែលជាពន្ធនាគារចង្អៀតណែនបំផុតផ្ទុកចំនួន ២៩៦% នៃទំហំផ្ទុកនៃពន្ធនាគារនេះ។

ក្នុងកាលៈទេសៈបែបនេះ វាមិនសមហេតុផលទាល់តែសោះ ដែលត្រូវទុកជនជាប់ឃុំនៅក្នុងពន្ធនាគារទាំងនេះ ដោយគ្មានពេលកំណត់ ឬសូម្បីទុកតែរយៈពេល ២ ឬ ៣ ខែក៏ដោយ ក្រោយពីបានធ្វើសវនាការលើបណ្តឹងឧទ្ធរណ៍រួច។ ពិតណាស់ ឯកឧត្តម គុយ ប៊ុនសន អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ បានទទួលស្គាល់បញ្ហានេះដោយផ្ទាល់ នៅអំឡុងពេលកិច្ចពិភាក្សាគណៈវាគ្មិនក្នុងសិក្ខាសាលាក្នុងខែកញ្ញា ឆ្នាំ២០១២។ ឯកឧត្តមបានធ្វើការកត់សំគាល់ថា ជនជាប់ឃុំ ត្រូវតែផ្ទេរទៅកាន់មណ្ឌលអប់រំកែប្រែទី១ មណ្ឌលអប់រំកែប្រែទី២ ពន្ធនាគារក្រុងតាខ្មៅ និងពន្ធនាគារប៉េហ្ស៊ី (PJ) សម្រាប់រង់ចាំសវនាការលើបណ្តឹងឧទ្ធរណ៍ "ទោះជាការធ្វើដូច្នេះជាការធ្វើឲ្យបញ្ហាកាន់តែធ្ងន់ធ្ងរ ដោយសារតែកំរិតនៃភាពចង្អៀតណែននៅក្នុងពន្ធនាគារ និងនៅក្នុងមណ្ឌលអប់រំកែប្រែទាំងនេះក៏ដោយ"[១១]។

ដោយបានឃើញចំនួនសរុបនៃការផ្ទេរជនជាប់ឃុំ មកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍ ដែលបានធ្វើនៅឆ្នាំ២០១២ ដូច្នេះយើងខ្ញុំហាក់ដូចជាមិនយល់ផងដែរ ដែលថា ហេតុអ្វីបានជាខ្វះមធ្យោបាយដឹកជញ្ជូនអ្នកទាំងនោះ ពីរាជធានីភ្នំពេញវិលត្រឡប់ទៅកាន់ខេត្តវិញ។ យោងតាមរបាយការណ៍ឆ្នាំ២០១២ របស់អគ្គនាយកដ្ឋានពន្ធនាគារជាឧទាហរណ៍ស្រាប់ មានការធ្វើដំណើរដាច់ដោយឡែកសរុបចំនួន ១៧៤ លើក ដែលត្រូវបានធ្វើឡើងដើម្បីផ្ទេរជនជាប់ឃុំមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍ រាប់ទាំងការធ្វើដំណើរចំនួន ១៨ លើក ដើម្បីផ្ទេរជនជាប់ឃុំពីខេត្តបាត់ដំបង។ នៅឆ្នាំ២០១២ អគ្គនាយកដ្ឋានពន្ធនាគារបានផ្ទេរជនជាប់ឃុំចំនួនសរុប ៦៨៦ នាក់ ទៅកាន់ពន្ធនាគារផ្សេងៗទៀត ដោយសារមានភាពចង្អៀតណែន។ ភាគច្រើនការផ្ទេរទាំងនេះ ត្រូវបានធ្វើឡើងទៅកាន់មណ្ឌលអប់រំកែប្រែទី៣

[១១] "ការលើកកំពស់កិច្ចសហការរវាងស្ថាប័នតុលាការ អយ្យការ និងពន្ធនាគារ និងការការពារសិទ្ធិកុមារក្នុងប្រព័ន្ធយុត្តិធម៌:របាយការណ៍សិក្ខាសាលាសហការរៀបចំដោយសាលាឧទ្ធរណ៍ ដោយមានការឧបត្ថម្ភពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា (OHCHR) និង UNICEF នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញកាលពីថ្ងៃទី៥-៧ ខែកញ្ញា ឆ្នាំ២០១២"។

និងមណ្ឌលអប់រំកែប្រែទី៤[១២]។

ប្រសិនបើមានរថយន្តដឹកជញ្ជូន ប្រេងសាំង និងបុគ្គលិកសម្រាប់ដឹកជញ្ជូនទៅពន្ធនាគារផ្សេងទៀត (ជាពិសេសទៅមណ្ឌលអប់រំកែប្រែទី៤ នៅពោធិ៍សាត់) យើងខ្ញុំសុំមេត្តាសួរសំនួរថា ហេតុអ្វីបានជាបន្ទាប់ពីសវនាការលើបណ្តឹងឧទ្ធរណ៍រួច ការធ្វើដំណើរវិលត្រឡប់ទៅខេត្តវិញ តែងតែមិនអាចធ្វើទៅបាន?

## ការផ្ទេរទៅកាន់មណ្ឌលអប់រំកែប្រែទី៣

ប្រហែលជាការវិវឌ្ឍន៍ ដែលគួរឲ្យព្រួយបារម្ភបំផុតទាក់ទងនឹងការដឹកជញ្ជូនមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍នោះ គឺជាការផ្ទេរជនជាប់ឃុំមួយចំនួន ដោយមិនមានការផ្ទេរវិលត្រឡប់ទៅកាន់ពន្ធនាគារខេត្តរបស់ពួកគេវិញ ប៉ុន្តែបែរជាការផ្ទេរឲ្យទៅរស់នៅក្នុងមណ្ឌលអប់រំកែប្រែទី៣ ក្នុងខេត្តកំពង់ចាមទៅវិញទេ។ មណ្ឌលអប់រំកែប្រែទី៣ នេះល្បីថាជាពន្ធនាគារមួយក្នុងចំណោមពន្ធនាគារ ដែលមានប្រព័ន្ធគ្រប់គ្រងមិនប្រក្រតីបំផុត ហើយមានទីតាំងដាច់ស្រយាលនៅជិតព្រំដែនវៀតណាម ដែលធ្វើឲ្យជនជាប់ឃុំទទួលការមកសួរសុខទុក្ខពីសំណាក់ក្រុមគ្រួសារ និងមិត្តភ័ក្តិចំនួនតិចតួច។ អ្នកស្រាវជ្រាវអង្គការលីកាដូ បានធ្វើសម្ភាសន៍ជាមួយជនជាប់ឃុំមួយចំនួនដែលអះអាងថា ជនជាប់ឃុំត្រូវបានផ្ទេរមកកាន់មណ្ឌលអប់រំកែប្រែទី៣ នេះបន្ទាប់ពីសវនាការលើបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងនោះ ដោយការបញ្ជូនត្រឡប់ទៅកាន់ពន្ធនាគារខេត្តដើមរបស់អ្នកទាំងនោះវិញ។ មណ្ឌលអប់រំកែប្រែទី៣ នេះ ក៏ទទួលរងនូវវិបត្តិនៃភាពចង្អៀតណែនផងដែរ។ មណ្ឌលអប់រំកែប្រែទី៣ នេះ បច្ចុប្បន្នកំពុងដំណើរការដោយមានទំហំផ្ទុក ១៩១% នៃសមត្ថភាពផ្ទុកតាមការគ្រោងទុក។

# ស្ថិតិឆ្នាំ២០១២-២០១៣

ថ្វីបើមានបញ្ហាបញ្ជូនជនជាប់ឃុំទៅកាន់ខេត្តវិញក៏ដោយ ខណៈមានភាពប្រសើរឡើងជាក់ស្តែងនៅអំឡុង ២ ឆ្នាំកន្លងមកនេះ ក៏ស្ថិតិថ្មីៗនេះបង្ហាញផងដែរថា ប្រព័ន្ធដឹកជញ្ជូនជនជាប់ឃុំមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍ គឺកំពុងព្យាយាមដោះស្រាយបញ្ហានៃចំនួនជនជាប់ឃុំយ៉ាងច្រើន ដែលកំពុងរង់ចាំសវនាការលើបណ្តឹងឧទ្ធរណ៍។

ចំពោះពន្ធនាគារចំនួន ៩ ដែលផ្តល់ទៅអង្គការលីកាដូ ក្នុងខែមីនា ឆ្នាំ២០១៣ អំពីទិន្នន័យជនជាប់ឃុំ ដែលកំពុងរង់ចាំសវនាការលើបណ្តឹងឧទ្ធរណ៍ ចំនួនជនជាប់ឃុំសរុបជាមធ្យម ១៥% នៃចំនួនជនជាប់ឃុំទាំងអស់ គឺកំពុងតែនៅរង់ចាំសវនាការលើបណ្តឹងឧទ្ធរណ៍។

ចំនួននេះ ជាតំណាងតួលេខ ដែលធ្លាក់ចុះត្រឹម ២% ដែលអង្គការលីកាដូ បានកត់ត្រាទុកក្នុងឆ្នាំ២០១២ (ចំនួនជនជាប់ឃុំនៅតាមពន្ធនាគារ ដែលអង្គការលីកាដូ បានធ្វើការឃ្លាំមើលបានធ្លាក់ចុះចំនួន ២.៨% ផងដែរចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០១២ ដល់ខែមីនា ឆ្នាំ២០១៣)។ សូមកត់សំគាល់ថា តារាងនេះ ដាក់បញ្ចូលតែពន្ធនាគារទាំងឡាយ ដែលបានផ្តល់ទិន្នន័យក្នុងឆ្នាំ២០១២ និងឆ្នាំ២០១៣។ ពន្ធនាគារចំនួន ២ ដែលបានរាយការណ៍អំពីទិន្នន័យក្នុងឆ្នាំ២០១២ (ខេត្តកំពត និងខេត្តសៀមរាប) មិនបានផ្តល់ទិន្នន័យជូនអង្គការលីកាដូ ទេ ក្នុងឆ្នាំ២០១៣។

| ពន្ធនាគារ | ជនជាប់ឃុំជាប់បណ្តឹងឧទ្ធរណ៍ ខែកុម្ភៈ ឆ្នាំ២០១២ | ចំនួនទណ្ឌិតសរុប ខែកុម្ភៈ ឆ្នាំ២០១២ | ជនជាប់ឃុំជាប់បណ្តឹងឧទ្ធរណ៍ ខែមីនា ឆ្នាំ២០១៣ | ចំនួនទណ្ឌិតសរុប ខែមីនា ឆ្នាំ២០១៣ |
|---|---|---|---|---|
| មណ្ឌលអប់រំកែប្រែទី៣ | ៣៥៦ | ១,៤៩០ (២៣.៩%) | ៣១០ | ១,៥៤៦ (២០.១%) |
| កំពង់សោម | ១៦ | ១៦០ (១០%) | ២២ | ២៤១ (៩.១%) |
| កំពង់ស្ពឺ | ៧០ | ២៥២ (២៧.៨%) | ៦០ | ១៩៦ (៣០.៦%) |
| កំពង់ឆ្នាំង | ២២ | ១២០ (១៨.៣%) | ១៦ | ៣១០(៥.២%) |
| កំពង់ធំ | ៣០ | ២៨២ (១០.៦%) | ៤៧ | ២៩០ (១៦.២%) |
| កោះកុង | ២៨ | ២០១ (១៣.៩%) | ២៨ | ១៨៥ (១៥.១%) |
| ពោធិ៍សាត់ | ២៨ | ១០៧ (២៦.២%) | ១៦ | ១២៦ (១២.៧%) |
| បាត់ដំបង | ៣៥ | ៩១០ (៣.៨%) | ២១ | ៧៩៥ (២.៦%) |
| ស្វាយរៀង | ៥៥ | ២១៦ (២៥.៥%) | ៦៣ | ២០៦ (៣០.៦%) |
| សរុប | ៦៤០ | ៣,៧៣៨ (១៧.១%) | ៥៨៣ | ៣,៨៩៥ (១៥.០%) |

[១២] របាយការណ៍ស្ថិតិប្រចាំឆ្នាំ២០១២ របស់អគ្គនាយកដ្ឋានពន្ធនាគារ "ការផ្ទេរជនជាប់ឃុំដើម្បីកាត់បន្ថយភាពចង្អៀតណែន" បោះពុម្ពផ្សាយនៅខែមីនា ឆ្នាំ២០១៣ (បកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការ)។

## ករណីរបស់សំណាង៖ ការស្តានីតិសម្បទា ដែលបានសន្យាត្រូវបានផ្អាក

"សំណាង" ភេទប្រុស (មិនមែនឈ្មោះពិតទេ) មកពីខេត្តសៀមរាប គឺជាជនជាប់ឃុំម្នាក់វ័យក្មេងដែលបានជាប់ខ្លួននៅមណ្ឌលអប់រំកែប្រែទី១ បន្ទាប់ពីត្រូវបានអគ្គនាយកដ្ឋានពន្ធនាគារដឹកមកកាន់រាជធានីភ្នំពេញ ដើម្បីចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់សំណាង។

សំណាងត្រូវបានចាប់ខ្លួន ក្នុងខែវិច្ឆិកា ឆ្នាំ២០០៨ ហើយកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន ៥ ឆ្នាំ ពីបទទម្លុះទម្លាយចូលក្នុងហាងលក់ដូរលួចទូរស័ព្ទ ១ គ្រឿង។ នៅពេលចាប់ខ្លួននោះ សំណាងទើបតែមានអាយុ ១៦ ឆ្នាំប៉ុណ្ណោះ។

នៅក្នុងពន្ធនាគារខេត្តសៀមរាប សំណាងទទួលបានឱកាសចូលរួមកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈរៀបចំឡើង ដោយអង្គការមិនមែនរដ្ឋាភិបាលមួយឈ្មោះថាកម្ពុជាជីវិតនេះ (This life Cambodia)។ កម្មវិធីនេះ ផ្តល់ដល់អនីតិជន ដែលជាប់ឃុំនៅក្នុងពន្ធនាគារនូវការបណ្តុះបណ្តាលជំនាញជួសជុលម៉ូតូ និងអគ្គិសនី ព្រមទាំងបំនិនជីវិត ការអភិវឌ្ឍន៍ដោយខ្លួនឯង និងការជួយឧបត្ថម្ភផ្នែកអប់រំពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ កម្មវិធីនេះ មានគោលដៅពង្រឹងការឲ្យតំលៃលើសមត្ថភាពខ្លួនឯង និងផ្តល់ឱកាសច្រើនថែមទៀតដល់អនីតិជន បន្ទាប់ពីពួកគេត្រូវបានដោះលែង ដូច្នេះវាកាត់បន្ថយបាននូវលទ្ធភាពក្នុងការប្រព្រឹត្តបទល្មើសសារជាថ្មីទៀត។

នៅក្នុងខែធ្នូ ឆ្នាំ២០១០ សំណាងចាប់ផ្តើមចូលរួមវគ្គបណ្តុះបណ្តាលជំនាញជួសជុលម៉ូតូ។ សម្រាប់វគ្គបណ្តុះបណ្តាលដែលមានរយៈពេលជាង ១ ឆ្នាំ សំណាងបានចូលរួមវគ្គបណ្តុះបណ្តាលនេះអស់រយៈពេលចំនួន ៣ ថ្ងៃពេញ។ ក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាល សំណាងបានទទួលវិញ្ញាបនប័ត្រខាងវិជ្ជាជីវៈនេះ ហើយសំណាងបានក្លាយជាអ្នកជំនួយការរបស់គ្រូបណ្តុះបណ្តាលបង្រៀនវិជ្ជាជីវៈ។ បុគ្គលិកអង្គការកម្ពុជាជីវិត បានពណ៌នាអំពីសំណាងថា ជាមនុស្សឧស្សាហ៍ ហើយជានិស្សិតដែលចូលចិត្តរៀនសូត្រ និងទទួលបាននូវការគោរពកោតសរសើរយ៉ាងខ្លាំងពីមនុស្សផ្សេងៗទៀត។

សំណាង ដែលបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការកាត់ទោសឲ្យជាប់ពន្ធនាគារ ៥ ឆ្នាំ ដោយយល់ដឹងពីសារៈសំខាន់ក្នុងការចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍ សំណាងមានសេចក្តីរីករាយដែលអគ្គនាយកដ្ឋានពន្ធនាគារបានដឹកដោយឥតបង់ថ្លៃពីខេត្តសៀមរាប ដើម្បីឲ្យសំណាងអាចមកចូលរួមសវនាការបានលើបណ្តឹងឧទ្ធរណ៍ ដោយផ្ទាល់។ រថយន្តអគ្គនាយកដ្ឋានពន្ធនាគារ បានមកដឹកសំណាងយកទៅមណ្ឌលអប់រំកែប្រែទី១ នៅជាយរាជធានីភ្នំពេញ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ មុនខែកញ្ញា ឆ្នាំ២០១២ ដែលជាខែកំណត់បើកសវនាការ។

ជាអកុសលសេចក្តីសម្រេចនេះ ធ្វើឲ្យការវិវឌ្ឍន៍នៃជំនាញខាងវិជ្ជាជីវៈ និងការជួយឧបត្ថម្ភផ្ទាល់ខ្លួនរបស់សំណាងត្រូវកាត់បន្ថយ។ អស់រយៈពេលជាង ៩ ខែ ក្រោយពីសវនាការលើបណ្តឹងឧទ្ធរណ៍ សំណាងនៅតែស្ថិតក្នុងមណ្ឌលអប់រំកែប្រែទី១ ដដែល។ នៅពេលសំណាងទទួលយកសំណើពីអគ្គនាយកដ្ឋានពន្ធនាគារ ដើម្បីដឹកមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍ គ្មានអ្នកណាបានពន្យល់ប្រាប់សំណាងថានឹងអាចជួបការលំបាក ក្នុងការវិលត្រឡប់ទៅកាន់ខេត្តសៀមរាបវិញនោះឡើយ។

អង្គការលីកាដូ ត្រូវបានគេប្រាប់ថា មានតែជនជាប់ឃុំទាំងឡាយដែលមានលុយ ទើបអាចវិលត្រឡប់ទៅកាន់ខេត្តរបស់អ្នកទាំងនោះវិញបាន បន្ទាប់ពីបានចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍នៅរាជធានីភ្នំពេញ។ សំណាងធ្វើការប៉ាន់ប្រមាណថា នឹងត្រូវបង់ប្រាក់ទៅឲ្យអាជ្ញាធរពន្ធនាគារពី ២០០ដុល្លារ ទៅ ៣០០ដុល្លារអាមេរិក ប្រសិនបើសំណាងចង់វិលត្រឡប់ទៅខេត្តសៀមរាបវិញ។ ជនជាប់ឃុំម្នាក់ទៀតមកពីខេត្តសៀមរាបដូចគ្នា ត្រូវបានគេប្រាប់ថា គាត់នឹងត្រូវបង់ប្រាក់ ៣០០ ដុល្លារ ប្រសិនបើគាត់ចង់ឲ្យអគ្គនាយកដ្ឋានពន្ធនាគារដឹកគាត់វិលត្រឡប់ទៅខេត្តសៀមរាបវិញ។

សំណាង មិនអាចមានលទ្ធភាពចូលរួមក្នុងឱកាសបណ្តុះបណ្តាលនៅមណ្ឌលអប់រំកែប្រែទី១ ឡើយ ហើយគ្រាន់តែត្រូវបានអនុញ្ញាតឲ្យចេញក្រៅបន្ទប់របស់គាត់ពីរដងក្នុងមួយសប្តាហ៍ ដែលត្រូវចំណាយពេលប្រហែល ១ ម៉ោង សម្រាប់ពេលចេញម្តងៗ។

ការទំនាក់ទំនងជាមួយក្រុមគ្រួសាររបស់សំណាង ក៏ទទួលរងផលប៉ះពាល់បែបនេះផងដែរ។ ក្នុងរយៈពេល ៩ ខែកន្លងទៅក្រុមគ្រួសាររបស់សំណាង អាចមានលទ្ធភាពមកសួរសុខទុក្ខសំណាងចំនួនតែ ២ ដងប៉ុណ្ណោះ ដោយសារផ្លូវឆ្ងាយ និងពេលវេលាមានកំរិតទាក់ទងនឹងការធ្វើដំណើរមករាជធានីភ្នំពេញ។ ផ្ទុយទៅវិញនៅអំឡុងខែមករា ឆ្នាំ២០១១ រហូតដល់ខែកុម្ភៈ ឆ្នាំ២០១២ ក្រុមគ្រួសារសំណាងអាចមកជួបគាត់បានចំនួន ១៤ ដង នៅពន្ធនាគារខេត្តសៀមរាប។

សំណាងល្អការសម្រេចរបស់ សំណាង ដើម្បីចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍មានលទ្ធផលជាវិជ្ជមាន ដោយសាលាឧទ្ធរណ៍បានបន្ថយទោសរបស់គាត់នៅសាលាដំបូងចំនួន ៦ ខែ ហើយសំណាងនឹងត្រូវដល់ពេលកំណត់ដោះលែង នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ ខាងមុខនេះ។ នៅពេលសំណាងត្រូវដោះលែងត្រឡប់ទៅផ្ទះសម្បែងវិញ សំណាងមានគម្រោងនឹងចូលរួមវគ្គបណ្តុះបណ្តាលបែបរំលឹកជាមួយអង្គការកម្ពុជាជីវិតនេះ ដើម្បីជាជំនួយដល់ការវិលចូលក្នុងសង្គមវិញ។

# អតុល្យភាពខាងយេនឌ័រ

យោងតាមស្ថិតិទូទាំងប្រទេសផ្ទាល់ របស់អគ្គនាយកដ្ឋានពន្ធនាគារ គិតមកត្រឹមខែវិច្ឆិកា ឆ្នាំ២០១២ មានជនជាប់ឃុំនៅជាប់បណ្តឹងឧទ្ធរណ៍ចំនួន ១,៤៧៤ នាក់ក្នុងចំណោមជនជាប់ឃុំចំនួនសរុប ១១,៨០៦ នាក់ (១២.៥% នៃជនជាប់ចោទសរុប)។ គួរឲ្យព្រួយបារម្ភផងដែរ ដែលស្ថិតិរបស់អគ្គនាយកដ្ឋានពន្ធនាគារបង្ហាញថា ជនជាប់ឃុំជាស្ត្រីចំនួន ២១% ក្នុងចំណោមជនជាប់ឃុំ ជាស្ត្រីទាំងអស់ កំពុងនៅរង់ចាំសវនាការលើបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងនោះ នៅឡើយ (ជនជាប់ឃុំជាស្ត្រីកំពុងរង់ចាំសវនាការលើបណ្តឹងឧទ្ធរណ៍ ចំនួន ១៨៩ នាក់ ក្នុងចំណោមជនជាប់ឃុំដែលជាស្ត្រីសរុប៩០៣ នាក់)[១៣]។

វាពិតណាស់ស្ថិតិរបស់អគ្គនាយកដ្ឋានពន្ធនាគារ បង្ហាញថែមទៀតថា ទន្ទឹមនឹងជនជាប់ឃុំចំនួន ១២.៨% ក្នុងចំណោមជនជាប់ឃុំទាំងនោះ ដែលកំពុងរង់ចាំសវនាការលើបណ្តឹងឧទ្ធរណ៍ គឺជាស្ត្រីមានជនជាប់ឃុំចំនួនតែ ៣.៩% ប៉ុណ្ណោះក្នុងចំណោមជនជាប់ឃុំទាំងនោះ ដែលត្រូវបានផ្ទេរមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍ គឺជាស្ត្រី [១៤]។

គួរឲ្យឆ្ងល់យ៉ាងខ្លាំង នៅពេលដែលមានជនជាប់ឃុំចំនួនជិត ៧០% នៅមណ្ឌលអប់រំកែប្រែទី២ នៅជាយរាជធានីភ្នំពេញជាស្ត្រី ក្នុងចំណោមជនជាប់ឃុំចំនួន ១៩ នាក់ ត្រូវបានដឹកយកមករក្សាទុកនៅជិតសាលាឧទ្ធរណ៍ គឺមានជនជាប់ឃុំតែម្នាក់ប៉ុណ្ណោះជាស្ត្រី។ មណ្ឌលអប់រំកែប្រែទី២ មិនផ្តល់ឲ្យអង្គការលីកាដូ នូវស្ថិតិស្តីពីចំនួនជនជាប់ឃុំប៉ុន្មាននាក់ ប្រុសប៉ុន្មាននាក់ ស្រីប៉ុន្មាននាក់ ដែលកំពុងរង់ចាំសវនាការលើបណ្តឹងឧទ្ធរណ៍ទេ។

ចំនួនសមាមាត្រខ្ពស់នៃជនជាប់ឃុំជាស្ត្រី ដែលកំពុងរង់ចាំសវនាការលើបណ្តឹងឧទ្ធរណ៍ អាចឆ្លុះបញ្ចាំងនូវការកើនឡើងជាសមាមាត្រចំពោះជនជាប់ឃុំជាស្ត្រី នៅអំឡុងពេលជាង ២ ឆ្នាំ កន្លងមកនេះ។ នៅក្នុងខែមីនា ឆ្នាំ២០១៣ អង្គការលីកាដូ បានរាយការណ៍ថា នៅក្នុងប្រព័ន្ធគ្រប់គ្រងពន្ធនាគារកម្ពុជា ជនជាប់ឃុំជាស្ត្រីមានចំនួនកើនឡើង ៣៩% ហើយ នៅពេលដែលស្ត្រី និងក្មេងស្រីមាន ៨% នៃចំនួនជនជាប់ឃុំក្នុងពន្ធនាគារនោះ អត្រាឃុំខ្លួនរបស់អ្នកទាំងនោះ កំពុងតែបានកើនឡើង ៤ដង រហ័សជាងចំនួនជនជាប់ឃុំជាបុរសនៅតាមពន្ធនាគារ[១៥]។

អតុល្យភាពខាងយេនឌ័រជាក់ស្តែង ក្នុងការដឹកជនជាប់ឃុំមកចូលរួមស វនាការលើបណ្តឹងឧទ្ធរណ៍អាចជាសញ្ញា នៃបញ្ហាដែលមានជាប់មកជាមួយនៅក្នុងប្រព័ន្ធគ្រប់គ្រងពន្ធនាគារដោយផ្ទាល់ផងដែរ។ ដូចអគ្គនាយកដ្ឋានពន្ធនាគារអះអាង ប្រសិនបើអគ្គនាយកដ្ឋាននេះ



អ្នកជាប់ឃុំជាស្ត្រីនៅក្នុងមណ្ឌលអប់រំកែប្រែទី២ នៃរាជធានីភ្នំពេញ

**ទីនៅពេលដែលមានជនជាប់ឃុំចំនួនជិត ៧០% នៅមណ្ឌលអប់រំកែប្រែទី២ នៅជាយរាជធានីភ្នំពេញជាស្ត្រី ក្នុងចំណោមជនជាប់ឃុំចំនួន ១៩ នាក់ ត្រូវបានដឹកយកមករក្សាទុកនៅជិតសាលាឧទ្ធរណ៍ គឺមានជនជាប់ឃុំតែម្នាក់ប៉ុណ្ណោះជាស្ត្រី។**

[១៣] អគ្គនាយកដ្ឋានពន្ធនាគារ "របាយការណ៍ប្រចាំឆ្នាំ២០១២ និងទិសដៅសម្រាប់ឆ្នាំ២០១៣" បោះពុម្ពផ្សាយនៅខែមីនា ឆ្នាំ២០១៣ (បកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការ)។
[១៤] យោងឯកសារដូចគ្នានឹងជើងទំព័រទី១៥។
[១៥] អង្គការលីកាដូ គូសបញ្ជាក់នូវការកើនឡើង គួរឲ្យព្រួយបារម្ភចំពោះជនជាប់ឃុំជាស្ត្រី ដើម្បីប្រារព្ធទិវាសិទ្ធិនារីអន្តរជាតិនៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៣។

នៅតែខ្វះធនធានមិនគ្រប់គ្រាន់សម្រាប់ធ្វើការផ្ទេរ នេះទំនងជាស្ត្រីមកពីពន្ធនាគារតាមខេត្ត នឹងក្លាយទៅជាអាទិភាពមួយទាបជាង។

នៅពេលធ្វើការផ្ទេរ ស្ត្រីគួរតែរក្សាទុកដាច់ដោយឡែកពីបុរស ហេតុដូច្នេះ ធ្វើឲ្យការធ្វើដំណើរមានការចាំបាច់ថែមទៀត ដោយត្រូវចំណាយថវិកាបន្ថែម។ នៅពេលធ្វើការដឹកជញ្ជូន ជនជាប់ឃុំជាស្ត្រីគួរតែត្រូវអមដំណើរ ដោយបុគ្គលិកពន្ធនាគារជាស្ត្រីផងដែរ។ ដោយសារតែបុគ្គលិកពន្ធនាគារកម្ពុជាជាបុរស[១៦] មានចំនួនដល់ទៅ ៩០% ស្ថាប័នពន្ធនាគារនីមួយៗនោះ អាចមិនមានបុគ្គលិកជាស្ត្រីគ្រប់គ្រាន់សម្រាប់អមការធ្វើដំណើរបែបនេះឡើយ។

ជនជាប់ឃុំជាស្ត្រីមកពីពន្ធនាគារតាមបណ្តាខេត្ត ជាពិសេសអាចមានភាពស្ទាក់ស្ទើរ មិនចង់ធ្វើដំណើរមកកាន់រាជធានីភ្នំពេញ ដើម្បីចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងនោះ ប្រសិនបើពួកគេដឹងថានឹងជាប់ខ្លួននៅក្នុងរាជធានីភ្នំពេញ ជាពិសេសប្រសិនបើអ្នកទាំងនោះមានកូនតូច ឬមានការទទួលខុសត្រូវក្នុងការថែទាំកូនៗ។

# សេចក្តីសន្និដ្ឋាន និងយោបល់មួយចំនួន

ឯកឧត្តម គុយ ប៊ុនសន អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារបានទទួលស្គាល់ដោយផ្ទាល់ អំពីបញ្ហាដឹកជញ្ជូនជនជាប់ឃុំនៅតែជា "បញ្ហាកំពុងប្រឈមមុខយ៉ាងខ្លាំងសម្រាប់ អគ្គនាយកដ្ឋានពន្ធនាគារ"[១៧] នៅឡើយ។ ឯកឧត្តម យូ ប៊ុនឡេង ប្រធានសាលាឧទ្ធរណ៍បានថ្លែងផងដែរថា ថ្វីបើចំនួនចៅក្រមនៅសាលាឧទ្ធរណ៍បច្ចុប្បន្ននេះបានកើនឡើង ហើយសាលាឧទ្ធរណ៍មានបន្ទប់សវនាការបន្ថែមមួយទៀតក៏ដោយ ក៏ "នៅតែត្រូវការប្រើពេលវេលា ដើម្បីកាត់បន្ថយការកកស្ទះនៃសំណុំរឿងឧទ្ធរណ៍ផងដែរ[១៨]"។

ការផ្ទេរជនជាប់ឃុំមកចូលរួមសវនាការ លើបណ្តឹងឧទ្ធរណ៍ ប៉ុន្តែមិនបានបញ្ជូនអ្នកទាំងនោះ ត្រឡប់ទៅពន្ធនាគារខេត្តវិញ នឹងធ្វើឲ្យបញ្ហាប្រឈម ដែលមានស្រាប់កាន់តែមានភាពធ្ងន់ធ្ងរឡើងប៉ុណ្ណោះ។ ដូចអង្គការលីកាដូ បានចងក្រងទុកជាឯកសារ ជនជាប់ឃុំកាន់តែមានភាពស្ទាក់ស្ទើរ មិនចង់មកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងនោះ ដោយសារតែមានបញ្ហាបែបនេះ។ ការសន្និដ្ឋានធម្មតាមួយសម្រាប់ជនជាប់ឃុំខ្លះ នឹងមិនមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍ឡើយ។ លើសពីនេះទៅទៀត ការរក្សាទុកជនជាប់ឃុំនៅក្នុងពន្ធនាគាររាជធានីភ្នំពេញ គឺជាការដាក់សម្ពាធបន្ថែមទៅលើពន្ធនាគារ ដែលមានភាពចង្អៀតណែនរួចទៅហើយ។

ការដឹកជញ្ជូនជនជាប់ឃុំ មកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍បច្ចុប្បន្ននេះ ជាក់ស្តែងនៅតែមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីបំពេញសេចក្តីត្រូវការ របស់ប្រព័ន្ធគ្រប់គ្រងពន្ធនាគារទាំងមូលឡើយ ។ នៅក្នុងឆ្នាំ២០១២ អង្គការលីកាដូ បានស្នើសុំឲ្យមានដំណោះស្រាយបន្ថែមផ្សេងៗទៀតដែលអាចធ្វើបាន ដើម្បីសម្រួលដល់ការកកស្ទះសំណុំរឿងនេះ ហាក់ដូចជានៅពេលសំណើទាំងនេះ ត្រូវបានពិនិត្យក៏ដោយ ប៉ុន្តែរហូតមកទល់ពេលនេះគ្មានវិធានការច្បាស់លាស់ ឬក៏មានតិចតួចត្រូវបានចាត់ឲ្យមានឡើងទៅវិញៈ

## "ការរៀបចំជាក្រុម" នូវសវនាការលើបណ្តឹងឧទ្ធរណ៍

អ្នកចូលរួមសិក្ខាសាលាក្នុងខែកញ្ញា ឆ្នាំ២០១២ ដែលសហការរៀបចំដោយសាលាឧទ្ធរណ៍បានឯកភាព និងលើកជាអនុសាសន៍ថា លទ្ធភាព "ក្នុងការរៀបចំជាក្រុម" នូវសវនាការលើបណ្តឹងឧទ្ធរណ៍គួរតែត្រូវ "ពិនិត្យពិចារណា" ដើម្បីសម្រួលដល់វត្តមានរបស់ជនជាប់ចោទនៅពេលសវនាការលើបណ្តឹងឧទ្ធរណ៍។ ឯកឧត្តម ប៊ុន ហ៊ុន អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌បានឯកភាពថាប្រការនេះ ត្រូវការឲ្យមានកិច្ចសម្របសម្រួលរវាងសាលាឧទ្ធរណ៍ និងអគ្គនាយកដ្ឋានពន្ធនាគារ ប៉ុន្តែកិច្ចការនេះត្រូវតែអាចធ្វើទៅបាន។ អ្នកចូលរួមបានឯកភាពគ្នាថា សាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញា និងអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ត្រូវពិភាក្សាគ្នាកម្មវិធីបាយ "រៀបចំជាក្រុម" នូវសវនាការទៅលើបណ្តឹងឧទ្ធរណ៍[១៩]។ ថ្វីត្បិតតែយើងពេញចិត្តនឹងអនុសាសន៍នេះ ដែលកំពុងត្រូវបានពិនិត្យពិចារណាដោយរាជរដ្ឋាភិបាល ប៉ុន្តែក៏ជាការខកចិត្តដែលថាគ្មានវិធានការច្បាស់លាស់ទំនងត្រូវបានចាត់ឲ្យមានឡើងនោះទេមកទល់នឹងពេលនេះ។

## ការបង្កើតសាលាឧទ្ធរណ៍នៅក្នុងកម្រិតតំបន់

មន្ត្រីក្រសួងយុត្តិធម៌មួយរូប បានប្រាប់កាសែតភ្នំពេញប៉ុស្តិ៍ ក្នុងខែឧសភា ឆ្នាំ២០១២ ថាប្រព័ន្ធគ្រប់គ្រងសាលាឧទ្ធរណ៍កម្រិតតំបន់នឹងត្រូវបង្កើតឲ្យមានឡើង ប៉ុន្តែមិនបានមានប្រសាសន៍ថានៅពេលណា និងនៅកន្លែងណានោះទេ[២០]។ អ្នកចូលរួមសិក្ខាសាលាក្នុងខែកញ្ញា ឆ្នាំ២០១២ បានឯកភាពគ្នា និងលើកជាអនុសាសន៍ផងដែរថា ការបង្កើតសាលាឧទ្ធរណ៍នៅកម្រិតតំបន់ គួរតែត្រូវបានបង្កើតឡើង "ឲ្យបានឆាប់តាមដែលអាចធ្វើបាន"[២១]។ អង្គការលីកាដូ សូមស្វាគមន៍នូវអនុសាសន៍នេះ ហើយសង្ឃឹមពរដោយទទូចថា ធនធានត្រូវតែបានផ្តល់ ដើម្បីអនុវត្តអនុសាសន៍នេះឲ្យបានឆាប់។

## សាលាឧទ្ធរណ៍ចល័ត

អង្គការលីកាដូ មិនបានដឹងអំពីកិច្ចពិភាក្សាគ្នាបន្ថែម ដែលបានកើតឡើងទាក់ទងនឹងលទ្ធភាពដាក់ចេញ នូវសាលាឧទ្ធរណ៍ចល័តឡើយ។

## សវនាការតាមរយៈប្រព័ន្ធវីដេអូអ៊ីនធឺណិត (Videoconferencing)

អង្គការលីកាដូ បានលើកសំណើថា បច្ចេកទេសនេះ អាចត្រូវប្រើសម្រាប់គោលបំណង ដែលមានដែនកំណត់តែប៉ុណ្ណោះ ដូចជាត្រូវប្រើសម្រាប់សាក្សីផ្តល់សក្ខីកម្ម។ អ្នកចូលរួមសិក្ខាសាលាក្នុងខែកញ្ញា ឆ្នាំ២០១២ បានពិភាក្សាគ្នាពីលទ្ធភាពនេះ ហើយគំនិតនេះ ត្រូវបានស្វាគមន៍ដោយឯកឧត្តម យូ ប៊ុនឡេង ប្រធានសាលាឧទ្ធរណ៍។

[១៧] អគ្គនាយកដ្ឋានពន្ធនាគារ "របាយការណ៍ប្រចាំឆ្នាំ២០១២ និងទិសដៅសម្រាប់ឆ្នាំ២០១៣" បោះពុម្ពផ្សាយនៅខែមីនា ឆ្នាំ២០១៣ (បកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការ)។
[១៨] យោងឯកសារដូចគ្នានឹងជើងទំព័រទី១៩។
[១៩] យោងឯកសារដូចគ្នានឹងជើងទំព័រទី២០។
[២០] Shane Worrell និង Chhay Channyda "ប្រព័ន្ធគ្រប់គ្រងសាលាឧទ្ធរណ៍កម្រិតតំបន់នឹងត្រូវបង្កើតឲ្យមានឡើង "កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១២។
[២១] យោងឯកសារដូចគ្នានឹងជើងទំព័រទី២២។

អនុសាសន៍នានាពីអង្គសិក្ខាសាលានេះ បានកត់សំគាល់ថា មធ្យោបាយនេះ នឹងមាន “ប្រ យោជន៍” ដើម្បីបង្កើតមធ្យោបាយសវនាការតាមរយៈប្រព័ន្ធវីដេអូអ៊ីនធឺណិត ដើម្បីអនុញ្ញាតឲ្យជនជាប់ឃុំ និងសាក្សីច្រើនថែមទៀត “ចូលរួម” សវនាការលើបណ្តឹងឧទ្ធរណ៍។ ប្រការនេះ គួរឲ្យលើកទឹកចិត្ត ប៉ុន្តែអង្គការលីកាដូ សូមរំលឹកឡើងវិញថា មានដែនកំណត់ជាច្រើន អំពីការប្រើសវនាការតាមរយៈប្រព័ន្ធវីដេអូអ៊ីនធឺណិតជាមធ្យោបាយតែមួយគត់ សម្រាប់ជនជាប់ឃុំចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងនោះ។ ដូចបានកត់សំគាល់ក្នុងរបាយការណ៍ឆ្នាំ២០១២ របស់អង្គការលីកាដូ ស្តីពីបណ្តឹងឧទ្ធរណ៍មានដែនកំណត់ជាច្រើន ក្នុងការដាក់ឲ្យប្រើប្រាស់បច្ចេកទេសនេះ ចំពោះសាលាឧទ្ធរណ៍នៅកម្ពុជា។ ប្រការដែលគួរឲ្យកត់សំគាល់បំផុតនោះ គឺការប្រើបណ្តាញបញ្ជូនរូបភាព និងសំឡេងដោយភ្ជាប់ប្រព័ន្ធវីដេអូ អាចមានអនុភាពគម្លាតដាច់ពីគ្នារវាងចុងចោទ និងអ្នកចូលរួមផ្សេងៗទៀត។ ចុងចោទនឹងមានការយល់ដឹងតិចតួច (ហើយតាមន័យត្រង់ការមើលឃើញរូបភាពមានកម្រិត ដោយផ្អែកលើអ្វីដែលប្រព័ន្ធវីដេអូបានបង្ហាញ) ពីចំណាត់ការនីតិវិធីក្នុងបន្ទប់សវនាការ[២២]។ ការចំណាយទៅលើប្រព័ន្ធបែបនេះ នឹងមានតម្លៃថ្លៃផងដែរ ហើយថវិកាដ៏តិចតួច ទំនងជាត្រូវចំណាយឲ្យបានសមរម្យទៅលើចៅក្រម បន្ទប់សវនាការ និងទៅលើហេដ្ឋារចនាសម្ព័ន្ធសម្រាប់ដឹកជញ្ជូនជនជាប់ឃុំច្រើនថែមទៀត។

## យោបល់មួយចំនួន

►►► ជាថ្មីម្តងទៀតអង្គការលីកាដូ សំណូមពរដោយទទូច សូមអាជ្ញាធរ លោកមេត្តាកំណត់មូលនិធិជាអាទិភាពសម្រាប់រថយន្តដឹកជញ្ជូននៅតាមពន្ធនាគារ និងប្រេងសាំង/ម៉ាស៊ូត សម្រាប់ជនជាប់ឃុំមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងនោះ និងដឹកអ្នកទាំងនោះត្រឡប់ទៅកាន់ពន្ធនាគារខេត្តវិញ។

►►► អង្គការលីកាដូ សូមស្វាគមន៍នូវអនុសាសន៍ទាំងឡាយ ពីអង្គសិក្ខាសាលាក្នុងខែកញ្ញា ឆ្នាំ២០១២ ហើយនឹងសូមសំណូមពរដោយទទូច សូមមេត្តាចាត់វិធានការច្បាស់លាស់ ដើម្បីអនុវត្តនូវអនុសាសន៍ទាំងអស់នេះ។

►►►ជនជាប់ឃុំទាំងឡាយ ដែលជាប់ខ្លួននៅក្នុងពន្ធនាគាររាជធានីភ្នំពេញ បន្ទាប់ពីបានមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍របស់អ្នកទាំងនោះ ហើយដែលមានបំណងចង់វិលត្រឡប់ទៅកាន់ពន្ធនាគារខេត្តវិញ គួរតែត្រូវផ្តល់មធ្យោបាយដឹកជញ្ជូនត្រឡប់ទៅវិញ ដោយឥតបង់ថ្លៃដោយគ្មានពន្យារពេល។

►►► សូមមេត្តាផ្តល់ដល់ជនជាប់ឃុំជាស្ត្រីនូវសិទ្ធិស្មើភាព ក្នុងការទទួលបានមធ្យោបាយដឹកជញ្ជូនពីអគ្គនាយកដ្ឋានពន្ធនាគារមកចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍ ហើយសូមមេត្តាកុំដកអ្នកទាំងនោះចេញ ដោយសារតែខ្វះធនធានឡើយ។

[២២] "ការលើកកំពស់កិច្ចសហការរវាងស្ថាប័នតុលាការ អយ្យការ និងពន្ធនាគារ និងការការពារសិទ្ធិកុមារក្នុងប្រព័ន្ធយុត្តិធម៌ៈរបាយការណ៍សិក្ខាសាលាសហការរៀបចំដោយសាលាឧទ្ធរណ៍ ដោយមានការឧបត្ថម្ភពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា (OHCHR) និង UNICEF នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញកាលពីថ្ងៃទី៥-៧ ខែកញ្ញា ឆ្នាំ២០១២"។

www.licadho-cambodia.org